## មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

## វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៉ម តំបន់ទី ៣

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃច័ន្ទ ទី០៣ ខែមេសា ឆ្នាំ២០០៦**

**ខេត្តមណ្ឌលគិរី**

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោក **ឡារី ស្រ្តេនឌ្ឌ** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម ដោយលោក ឱក សេរី សោភ័ក្តិ៍ ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

៣. ស្ថានភាពទូទៅ នៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក ទី ឈឿន ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តមណ្ឌលគិរី

៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តមណ្ឌលគិរី

៥. សេចក្តីផ្សេងៗ

លោក **ឱក សេរី សោភ័ក្តិ៍** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល

ខ្ញុំបាទជាទីប្រឹក្សានិងអ្នកសំរបសំរួលយន្តការខប់សែលសូមគោរពលោក Larry Strange ដែលជានាយកប្រតិបត្តិវិទ្យាស្ថាន CDRI សូមគោរពបង ទី ឈឿន ប្រធាន PEC នៅមណ្ឌលគិរី សូមគោរពលោកស្រី អស់លោក ទាំងអស់ដែលមានវត្តមាននៅទីនេះ។ ខ្ញុំបាទមានកិត្តិយសណាស់ដោយបានសំរបសំរួលយន្តការខប់សែល នៅមណ្ឌលគិរីថ្ងៃនេះ។ របៀបវារៈដែលអង្គប្រជុំស្នើឡើងគឺ យើងជជែកគ្នាដោយមិនចាំបាច់មានពិធីការច្រើនទេ ធ្វើយ៉ាងណាដើម្បីធ្វើឱ្យបរិយាកាសស្និទស្នាល ជជែកឱ្យបានសស្រាក់សស្រាំដើម្បីនឹងរកទាំងអស់គ្នានូវអ្វីដែលទាក់ទងទៅនឹងយន្តការបោះឆ្នោតនៅប្រទេសកម្ពុជារបស់យើង។

ជាបឋមខ្ញុំសូមអនុញ្ញាតិអញ្ជើញលោក Larry Strange ដែលជានាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដែលយើងហៅថា CDRI សូមលោកមានមតិស្វាគមន៍។

លោក **Larry Strange** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បី អភិវឌ្ឍន៍កម្ពុជា

ជាបឋមខ្ញុំបាទសូមគោរពចំពោះលោក ទី ឈឿន ដែលជាប្រធានគណកម្មការរៀបចំការបោះឆ្នោតប្រចាំ ខេត្តរតនៈគីរី សូមគោរពឯកឧត្តមអភិបាលរងខេត្តទី៣ ដែលឯកឧត្តមនឹងអញ្ជើញមកបន្តិចទៀតនេះ និងសូមគោរពចំពោះអស់លោក លោកស្រីទាំងអស់។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ឱក សេរី សោភ័ក្តិ៍ ដែលជាអ្នកសំរបសំរួលយន្តការខប់សែល និងក្រុមរៀបចំខប់សែលដែលបានរៀបចំវេទិកាប្រជុំនៅក្នុងថ្ងៃនេះ។ ឆ្លៀតនៅក្នុងឱកាសនេះខ្ញុំជំរាបជូនបន្តិចទាក់ទងទៅនឹងកិច្ចប្រជុំខប់សែលប្រ៉មនេះ គឺជាផ្នែកមួយសំខាន់បំផុតនៅក្នុងយន្តការបង្ការទំនាស់នៅក្នុងការបោះឆ្នោតនៅកម្ពុជាដែលយើងហៅកាត់ថាខប់សែលនេះ។ នៅក្នុងព្រឹកនេះខ្ញុំសូមបង្ហាញជូនថា តើហេតុអ្វីបានជា CDRI បង្កើតឱ្យមានកម្មវិធីយន្តការបង្ការទំនាស់នៅក្នុងការបោះឆ្នោត? វិទ្យាស្ថាន CDRI ធ្វើការពាក់ព័ន្ធទៅនឹងការស្រាវជ្រាវបញ្ហាផ្សេងៗនៅក្នុងស្រុកខ្មែរ ដើម្បីបង្កើតជាគោលនយោបាយសំរាប់ជូនអនុសាសន៍ទៅរាជរដ្ឋាភិបាល។ នៅក្នុងវិស័យផ្សេងៗដែលវិទ្យាស្ថាន CDRI បានធ្វើការកន្លងមកនេះ គឺជាពិសេសទាក់ទងទៅនឹងការស្រាវជ្រាវមានដូចជាសេដ្ឋកិច្ច និងពាណិជ្ជកម្ម កាត់បន្ថយភាពក្រីក្រ សន្តិសុខមនុស្ស ការដោះស្រាយទំនាស់ និងការកសាងសន្តិភាព អភិបាលកិច្ច ប្រជាធិបតេយ្យ និងការគ្រប់គ្រងធនធានធម្មជាតិ។ កម្មវិធីខប់សែលជាកម្មវិធីមួយសំខាន់ហើយជាផ្នែកមួយនៅក្នុងការជំរុញផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។ CDRI បានចាត់ទុកថាការបោះឆ្នោតមួយដែលប្រព្រឹត្តទៅបានល្អ និងទទួលបាន

ជោគជ័យគឺជាម៉ាស៊ីនមួយដែលជំរុញឱ្យមានការកសាងលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អនៅក្នុងប្រទេសកម្ពុជា ។ ចាប់តាំងពីយន្តការខប់សែលបានដំណើរការបន្ទាប់ពីបានបើកសន្និសីទជាផ្លូវការនៅក្នុងទីក្រុងភ្នំពេញ ខប់សែលបានបង្កើតនិងរៀបចំកម្មវិធីប្រជុំជាច្រើនទាំងនៅក្នុងទីក្រុងភ្នំពេញ ទាំងនៅតាមបណ្តាលខេត្តផ្សេងៗ ហើយក្នុងនោះខ្ញុំបានចូលរួមជាច្រើន ជាពិសេសខ្ញុំមានកិត្តិយសណាស់ដែលបានចូលរួមជួបជាមួយអស់លោក លោកស្រី នៅក្នុងថ្ងៃនេះ។ ចាប់តាំងពីកម្មវិធីខប់សែលបានអនុវត្តដំណើរការកន្លងមកនេះ យើងមានកិត្តិយសណាស់ដែលទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ភាគីពាក់ព័ន្ធផ្សេងៗ ជាពិសេសយើងបានទទួលការគាំទ្រពីខាងក្រសួងមហាផ្ទៃ គណកម្មាការជាតិរៀបចំការបោះឆ្នោត ខាងគណកម្មាការរៀបចំការបោះឆ្នោតខាងបណ្តាលខេត្តផ្សេងៗ ខាងអាជ្ញាធរនៅថ្នាក់ខេត្ត ថ្នាក់ស្រុក ក៏ដូចជានៅថ្នាក់ឃុំ ហើយបានទទួលការគាំទ្រនិងចូលរួមជាប្រចាំពីតំណាងគណបក្សនយោបាយទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការចូលរួមរបស់អស់លោក លោកស្រីគឺបានជំរុញឱ្យមាន ការពិភាក្សាដោយត្រង់ទៅវិញទៅមក និងប្រកបទៅដោយការគោរពគ្នាជាទីបំផុត។ ចំពោះរូបខ្ញុំផ្ទាល់ដែលមិនមែនជាប្រជាជនកម្ពុជា គឺទើបតែបានមកធ្វើការនៅស្រុកខ្មែរប្រហែល២ឆ្នាំកន្លះនេះ ខ្ញុំមានកិត្តិយសនិងមានសេចក្តីរីករាយបំផុត ដែលបានរៀនសូត្រអំពីកិច្ចប្រជុំខប់សែលយើងនេះ។ ជាការជំរុញឱ្យមានការពិភាក្សា ដើម្បីការកសាងវប្បធម៌នៃការជជែកពិភាក្សាគ្នា។

លោកឱក សេរី សោភក្តិ

ខ្ញុំបាទសូមថ្លែងនូវអំណរគុណលោក Larry Strange ដល់ជ្រាលជ្រៅជាទីបំផុតចំពោះប្រសាសន៍ដល់មានតំលៃ និងខ្លឹមសាររបស់លោកនៅជុំវិញយន្តការខប់សែល។ ខ្ញុំបាទសូមជំរាបប្រវត្តិខ្លីបន្តិចដើម្បីយើងយល់ថា ហេតុអ្វីបានជាយន្តការខប់សែលនេះកើតឡើង។ ខ្ញុំធ្លាប់បានធ្វើការតស៊ូនៅជាយដែន កាលជំនាន់នោះនៅក្មេងមកពីស្រុកបារាំងមកចូលធ្វើការតស៊ូ ហើយឃើញសោកនាដកម្មនៅជាយដែននៅពេលដែលយើងធ្វើសង្គ្រាម ធ្វើទាំងនយោបាយធ្វើទាំងខាងសឹក ហើយឃើញការស្លាប់ច្រើនណាស់បូករួមទាំងការសំលាប់រង្គាលជំនាន់ខ្មែរក្រហម។ ម្ល៉ោះហើយមានភាពតក់ស្លុតដោយជាប់នៅក្នុងខួរក្បាលថាស្រុកខ្មែរមិនគួរកាប់សំលាប់គ្នាអញ្ចឹង ហើយចេះតែបណ្តោយឱ្យស្លាប់តទៅទៀតទេគិតថាបើថ្ងៃណាមួយយើងចេញពីសង្គ្រាម ហើយរកសន្តិភាពបាននិងប៉ងប្រាថ្នាធ្វើយ៉ាងណាដើម្បីឱ្យមានយន្តការមួយដើម្បីឱ្យខ្មែរអាចនិយាយស្តាប់គ្នាបានដោយសន្តិវិធី ហើយដោយអហឹង្សា។ យើងអាចមានយោបល់ខុសគ្នា យើងអាចមានគំនិតមិនត្រូវគ្នា ក៏ប៉ុន្តែយើងអាចនិយាយគ្នាបានមិនចាំបាច់កាប់ចាក់គ្នាទេ បើមិនអញ្ចឹងទេស្រុកយើងគិតតែពីកសាងហើយបំផ្លាញ បំផ្លាញហើយកសាង ស្រុកគេឯទៀតៗគេជឿនលឿនអស់ហើយយើងទៅមិនរួចទេ។ ដល់មានសន្តិភាពមកខ្ញុំបាទក៏ទៅធ្វើការជាទីប្រឹក្សានិងជានាយកខុទ្ទកាល័យរបស់ឯកឧត្តម ស ខេង ៥ឆ្នាំ ពីឆ្នាំ ១៩៩៣ ដល់១៩៩៨ ក្នុង៥នេះបានរៀនសូត្រពីកិច្ចការរាជរដ្ឋាភិបាលបាន៥ឆ្នាំ ហើយក៏ជួយឯកឧត្តម ស ខេង ក្នុងរឿងយន្តការបោះឆ្នោតទៀត គឺរៀបចំការបោះឆ្នោតឆ្នាំ១៩៩៨ ក្រៅពីនោះមក រៀបចំការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០០២ គឺយើងបានគិតតាំងពីឆ្នាំ១៩៩៤ មកម្ល៉េះជាមួយឯកឧត្តម ស ខេង។ ជូនឯកឧត្តមចេញទៅក្រៅសុំជំនួយនៅក្នុងរឿងបោះឆ្នោត ហើយនៅពេលដែលខ្ញុំបាទនៅជាមួយឯកឧត្តម ស ខេង គឺខ្ញុំបាទបានទៅរៀនសូត្រពីវប្បធម៌សន្តិភាពនៅច្រើនប្រទេសណាស់ ហើយចេះតែនឹកឃើញថានៅពេលដែលចប់ធ្វើការជាមួយរាជរដ្ឋាភិបាល៥ឆ្នាំ ក៏ទៅចូលធ្វើការជាមួយនិងវិទ្យាស្ថាន CDRI នេះពីឆ្នាំ១៩៩៩ ដល់ ២០០៣។ នៅពេលធ្វើការនេះហើយដែលខ្ញុំបាទបានរៀនសូត្រច្រើនពីវប្បធម៌សន្តិភាព ហើយក៏បានរៀនសូត្រអំពីព្រះពុទ្ធសាសនាឡើងវិញ ដោយបានជួបជាមួយព្រះសង្ឃច្រើនណាស់ រៀនធ្វើសមាធិដើរមើលស្រុកទេសច្រើនបានឃើញថាសង្គមរបស់យើងជាសង្គមមួយដែលខ្ទេចខ្ទាំទាំងក្នុងចិត្ត ទាំងហេដ្ឋារចនាសម្ព័ន្ធ ប៉ុន្តែខ្ទេចខ្ទាំជាពិសេសគឺនៅក្នុងចិត្តនៅក្នុងបេះដូងយើងម្នាក់ៗ។ អញ្ចឹងហើយបានជានៅពេលដែលខ្ញុំទៅធ្វើការនៅក្នុងកម្មវិធីសន្តិភាពរបស់វិទ្យាស្ថាន

CDRI ឆ្នាំ១៩៩៩ ខ្ញុំបាទក៏ធ្វើការរៀបចំជាយន្តការខប់សែលនេះឡើង គិតថានៅជុំវិញការបោះឆ្នោតគណបក្សនយោបាយធំៗទាំងបី រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល គជប គួរតែអាចជជែកគ្នាបានហើយនិងដោះស្រាយបញ្ហាទាំងឡាយដែលទាក់ទងការបោះឆ្នោត គឺត្រង់ទៅត្រង់មកតែម្តង។ ខ្ញុំបាទគិតថាយើងល្មមដល់ពេលមួយដែលយើងឈប់ជជែក និងចោទគ្នាពីក្រោយខ្នងទៀតទៅ មានការអីយកមកដាក់នៅលើតុមកហើយយើងដោះស្រាយជាមួយគ្នា។ បញ្ហាត្រូវតែមានដំណោះស្រាយរបស់វា ខ្ញុំបាទជឿអញ្ចឹងបើមិនថ្ងៃនេះ ថ្ងៃក្រោយ ព្រោះមិនអាចចេះតែឈ្លោះគ្នាតទៅទៀតបានទេ។ ត្រូវដល់ពេលណាមួយដើម្បីនិងស្រុះស្រួល ហើយការដែលឈានទៅរកការស្រុះស្រួលគឺការអង្គុយនិយាយគ្នាត្រង់ទៅត្រង់មក ព្រោះយើងបញ្ចប់សង្គ្រាមដើម្បីមកកសាងសន្តិភាព ហើយការកសាងសន្តិភាពគឺការកសាងវប្បធម៌នៃការជជែកពិភាក្សាគ្នាត្រង់ទៅត្រង់មក ទុកចិត្តគ្នាទៅវិញទៅមក។ ឆ្លៀតឱកាសនេះខ្ញុំបាទសូមធ្វើការសូមគោរពយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តម ញ៉ក់រ៉ាង ចាន់ អភិបាលរង។ ខ្ញុំបាទមានឱកាសបានជួបឯកឧត្តមនៅក្នុងសិក្ខាសាលាជនជាតិដើមភាគតិចច្រើនលើកហើយ ដូច្នេះសូមអនុញ្ញាតិគោរពឯកឧត្តមសារជាថ្មីម្តងទៀតហើយមានកិត្តិយសណាស់ ដែលឯកឧត្តមបានចូលរួមមានវត្តមាននៅកិច្ចប្រជុំខប់សែលប្រ៊ុមនេះ។ ដូច្នេះនៅពីឆ្នាំ១៩៩៩ រហូតដល់ឆ្នាំ២០០៣ យើងបានធ្វើខប់សែល កាលនោះអត់មានស៊ីទេមានតែខប់សែល ដែលខប់សែលពាក្យថ្លែងមកថា Conflict Prevention in Cambodian Election ហៅកាត់ថាខប់សែល គឺយន្តការបង្ការទំនាស់នៅក្នុងយន្តការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជា។ កាលនោះក្រសួងមហាផ្ទៃដែលខ្ញុំធ្លាប់ធ្វើការជាមួយឯកឧត្តម ស ខេង គឺគាំទ្រតែម្តងឯកឧត្តមលោកអញ្ជើញមកបើក។ សហប្រតិបត្តិការគ្នារវាង CDRI និងក្រសួងមហាផ្ទៃនេះហើយដែលជាគន្លឹះដែលនាំឱ្យមានការជជែកពិភាក្សាគ្នា ហើយក្នុងពេលប្រជុំទាំង៥០ ដងមិនដែលខានទេ គឺរាល់ខែយើងប្រជុំ ប៉ុន្តែកាលនោះយើងប្រជុំនៅតែថ្នាក់ជាតិរវាងគណបក្សធំៗទាំងបី រាជរដ្ឋាភិបាល មាន៥ក្រសួងមកតំណាង គជប សង្គមស៊ីវិល ដែលធ្វើការលទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោត និងម្ចាស់ជំនួយគេមកអង្គុយជុំវិញតុដូចយើង។ ប៉ុន្តែកាលនោះខ្ញុំបាទធ្វើតែនៅក៏រិតថ្នាក់ជាតិទេ គឺមួយខែម្តង ដល់យើងបោះឆ្នោតឆ្នាំ២០០៣ ហើយក៏ចប់យន្តការនេះគឺខែកញ្ញា ឆ្នាំ២០០៣ យើងបានធ្វើការបូកសរុបលទ្ធផល។ ប៉ុន្តែពេលដែល UNDP គាត់មើលរបាយការណ៍ហើយគាត់មើលឃើញតំលៃរបស់ COPCEL គាត់ជួបជាមួយលោក Larry Strange និងខ្ញុំបាទ។ គាត់ថាឥឡូវយើងចង់គាំទ្រយន្តការខប់សែលនេះឱ្យបន្តទៅទៀត ដើម្បីរៀបចំការបោះឆ្នោតព្រឹទ្ធសភា នៅខែ០១ ឆ្នាំ២០០៦ នេះ កាលនោះយើងជជែកជាមួយគាត់ថាឆ្នាំ២០០៤ ហើយបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧ ដែលមានពេលតែមួយឆ្នាំទៀតទេ ដើម្បីនិងរៀបចំនិងបោះឆ្នោតថ្នាក់ជាតិប្រហែលជាខែ ០៧ ខែ ០៨ ឆ្នាំ២០០៨ ។ គាត់ក៏និយាយប្រាប់លោក Lrry Strange ហើយនិងខ្ញុំបាទអញ្ចឹង ដល់យើងសំរេចចុះកុងត្រាជាមួយគ្នាទៅខ្ញុំបាទយកពេលទៅពិចារណាមើលស៊ីជំរៅ យកពេលដលខ្លួនទៅសមាធិ ទៅជជែកជាមួយព្រះសង្ឃ ទៅដើរលេងតាមភូមិ ឃុំ ស្រុកទៅ ក៏ខ្ញុំបាទរកឃើញថាយន្តការខប់សែលមិនគួរនៅថ្នាក់ជាតិមួយមុខទេ។ កិច្ចការដែលសំខាន់បំផុតហើយដែលបានវិភាគទំនាស់នៅក្នុងការ បោះឆ្នោតនៅប្រទេសកម្ពុជារបស់យើង គឺកើតឡើងនៅថ្នាក់មូលដ្ឋាន។ បើដោះស្រាយបញ្ហានេះបានទាំងអស់ បើបង្កើតនូវវប្បធម៌ជជែក ពិភាក្សាគ្នាឱ្យបានទាំងអស់នៅថ្នាក់មូលដ្ឋាន គឺថ្នាក់ជាតិមិនសូវមានបញ្ហាវីវរល់ប៉ុន្មានទេ។ ដូច្នេះហើយបានជាខ្ញុំបាទគូសវាសយន្តការនេះសារជាថ្មីម្តងទៀត។ នេះជាមោទនភាពរបស់យើង ពីឆ្នាំ១៩៩៣ មកយើងធ្លាប់ទទួលជំនួយធ្លាប់ទទួលគំរោងដែលជាគំនិតរបស់អ្នកក្រៅរបស់ម្ចាស់ជំនួយ គេយកមកស្រុកយើងប៉ុន្តែយន្តការខប់សែលនេះគឺខ្មែរសុទ្ធសាធតែម្តង ដែលខ្ញុំបាទបានគិតពិចារណាគូសវាសឡើងដោយមោទនភាព ហើយនៅពេលដែលគូសវាសគឺគិតទៅដល់សន្តិភាព គិតទៅដល់ការបំផ្លិចបំផ្លាញដែលធ្លាប់បានជួបកាលនៅជាយដែនក្តី ទៅដល់ការសម្លាប់រង្គាលរបស់ខ្មែរក្រហមក្តីគឺធ្វើ យ៉ាងណាដើម្បីកុំឱ្យខ្មែរនិងខ្មែរឈានទៅរកអតីតកាលទៀត។ ហើយអង្គការសហប្រជាជាតិគាត់ទទួលស្គាល់តំលៃនេះគាត់សូមឱ្យយើងបន្តទៅទៀត។ មានប្រទេសដូចជា អាហ្គានីស្តង់ ទីម័រខាងកើត គេបានមករៀនជាមួយខ្ញុំបាទថាតើយើង

ជួយប្រាប់គេថាគេយកយន្តការនេះទៅធ្វើការនៅក្នុងប្រទេសគេដែលទើបនិងចេញពីសង្គ្រាមដែរយ៉ាងម៉េចបាន។ ដូច្នេះហើយបានជាខ្ញុំបាទគិតស្រម័យឃើញយន្តការខប់សែលប្រ៉មនេះឡើង គឺ COPCEL Provincial Meeting ហើយនិងធ្វើនៅតាមខេត្តក្រុងទាំង២៤ ពីនេះទៅដល់២០០៨ ខេត្តនីមួយៗនិងធ្វើជំនុំគ្នា២ដង ហើយខ្ញុំបាទសង្ឃឹមថាបងប្រធាន PEC នៅគ្រប់ខេត្តទាំងអស់ ទាំងអង្គការសង្គមស៊ីវិល គណបក្សនយោបាយ លោកនិងជួបជុំគ្នា។ ខ្ញុំបាទដឹងថា PEC ក៏មានធ្វើការជួបប្រជុំគ្នាញឹកញាប់ដែរជាមួយគណបក្សនយោបាយនិងសង្គមស៊ីវិល នៅក្នុងនេះខ្ញុំបាទត្រេកអរណាស់នៅពេលដែលឃើញកិច្ចការទាំងអស់នេះកើតឡើង។ ដូច្នេះខប់សែលប្រ៉មជាយន្តការដែលមានរូបភាពច្រើនឆ្នាំរួចមកហើយ ដែលប្រទេសអ្នកផ្តល់ជំនួយរាជរដ្ឋាភិបាល សង្គមស៊ីវិលទាំងអស់ទទួលស្គាល់ជាផ្លូវការ ហើយអ្វីៗដែលឯកឧត្តម អស់លោក លោកស្រី នឹងមានប្រសាសន៍គឺនឹងកត់ចូល អញ្ចឹង ហើយបានយើងត្រូវនិយាយនៅក្នុងម៉ៃក្រូគេថតសំលេងទាំងអស់ ហើយកត់ចូលថ្វាយទៅព្រះមហាក្សត្រ ទៅ សម្តេចនាយក សម្តេចប្រធានសភា ព្រឹទ្ធសភា ទៅគ្រប់រដ្ឋមន្ត្រីនិងអង្គការពាក់ព័ន្ធជាតិនិងអន្តរជាតិទាំងអស់។ ពេលណាយើងជជែកគ្នាហើយយើងនៅតែអត់ស្របគ្នានេះជាការធម្មតា តែយើងចាប់ផ្តើមគោរពអ្នកដែលមានគំនិតខុសពីយើង។ យើងនិងបន្តជជែកគ្នាតទៅទៀត រហូតទាល់តែយន្តការបោះឆ្នោតនៅស្រុកខ្មែរក្លាយជាយន្តការមួយដែលមានសន្តិភាព ដែលអហឹង្សា ហើយដែលប្រជាពលរដ្ឋរបស់យើងទទួលស្គាល់ ហើយដែលសហគមន៏អន្តរជាតិទទួលស្គាល់ថាជាយន្តការមួយមានតំលៃពិតប្រាកដមែន។ ខប់សែលប្រ៉មដើរតួនាទីសំខាន់ណាស់ ព្រោះនៅក្នុងថ្ងៃនេះតួអង្គដែលសំខាន់គឺយើងបានយកខប់សែលប្រ៉ម មកបំរើក្រុមប្រឹក្សាឃុំសង្កាត់ អញ្ចឹងហើយបានជាយើងអញ្ជើញសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំង៣គណបក្សធំៗមកចូលរួម ដើម្បីឱ្យលោកមានប្រសាសន៍ថាតើនៅក៏រិតប្រជាពលរដ្ឋរបស់យើង នៅក្នុងជីវភាពប្រចាំថ្ងៃរបស់គាត់តើគាត់ជួបបញ្ហាអ្វីខ្លះដែលលំបាកនៅក្នុងការបោះឆ្នោត។ គោលដៅធំៗ៣ដែលយើងខ្ញុំចង់បានគឺះ

ទី១ លទ្ធផលធំណាស់បានសំរេចរួចហើយយើងនិងធ្វើចលនាឱ្យប្រជាពលរដ្ឋខ្មែរដែលអាយុ ១៨ ឆ្នាំ បានចុះឈ្មោះនៅតាមឃុំសង្កាត់ទាំងអស់ មានសំបុត្រកំណើត ជាពិសេសមានអត្តសញ្ញាណប័ណ្ណជាតិ។ រឿងនេះយើងធ្វើចលនាជាមួយនិងក្រសួងមហាផ្ទៃជាមួយនិងខេត្តឯទៀត ហើយប្រហែលជា៣-៤ខែជាប់ៗគ្នាទាំងអស់។ អញ្ចឹងហើយបានជាពីរខែមុនឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោកថ្លែងជាសាធារណៈថាមានយន្តការ ដើម្បីនិងគាំទ្រឱ្យអត្តសញ្ញាណប័ណ្ណជាតិនេះបានគ្រប់ទៅដល់ប្រជាពលរដ្ឋខ្មែរដែលមានអាយុ១៨ ឆ្នាំ ។ យន្តការនេះធំណាស់ ប៉ុន្តែលោកសំរេចហើយអាចនិងធ្វើទៅបាន ដែលនិងផ្តល់ជូនប្រជាពលរដ្ឋខ្មែរដែលនៅសល់ប្រហែលជាមួយលានប្រាំបួនសែនទៀត មិនទាន់បានទទួលអត្តសញ្ញាណប័ណ្ណ។ លោកក៏សំរេចដែរថាដើម្បីកុំឱ្យរាំងស្ទះកាលពីមុនមានតែចៅហ្វាយខេត្តទេដែលស៊ីញ៉េបាននៅក្នុងអត្តសញ្ញាណប័ណ្ណជាតិ ឥឡូវអភិបាលរងខេត្តទី១ លោកអាចទទួលប្រតិភូកម្មដើម្បីនិងស៊ីញ៉េ នៅពេលណាដែលឯកឧត្តមអភិបាលខេត្តលោកមិននៅ។ ដូច្នេះហើយក្រសួងលោកបានយកចិត្តទុកដាក់ណាស់នៅពេលដែលយើងជជែកទៅយើងឃើញបញ្ហាយើងទាមទារ គឺថារដ្ឋាភិបាលលោកឆ្លើយមកដោយវិជ្ជមានបែបហ្នឹង នេះជាជំហ៊ានមួយធំណាស់។ ហើយយើងសង្ឃឹមថាខប់សែលប្រ៉មដោយសារមានដូចថ្ងៃនេះមានវត្តមានរបស់ឯកឧត្តមអភិបាលរងលោកអញ្ជើញមកនេះជាការសំខាន់ណាស់ជាតឹកតាងនៃការគាំទ្រនៅក្នុងបញ្ហានេះ។ បងវិរសេនីយ៏ឯកតំណាងខាងប៉ូលីស លោកបានអញ្ជើញមានវត្តមានលោកពាក់ព័ន្ធផ្ទាល់នៅក្នុងរឿងអត្តសញ្ញាណប័ណ្ណជាតិ។ យើងធ្វើការរួមជាមួយ NGOs រដ្ឋាភិបាលធ្វើការរួមគ្នាជាមួយនិងអង្គការ UNDP ដែលគាំទ្រយន្តការខប់សែល ព្រោះគាត់ឱ្យជំនួយមកច្រើនណាស់ដើម្បីយើងបានចុះមកធ្វើការនៅគ្រប់ខេត្ត។

ទី២ គឺយើងធ្វើយ៉ាងណាដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់ជាពិសេសខេត្តដែលនៅឆ្ងាយដូចជាមណ្ឌលគិរី ខេត្តរតនគិរី ខេត្តស្ទឹងត្រែង បានចុះឈ្មោះបោះឆ្នោត។ ការចុះឈ្មោះពិបាកណាស់ព្រោះចំងាយផ្លូវហើយហេដ្ឋារចនាសម្ព័ន្ធរបស់យើងនៅមិនទាន់បានល្អ១00ភាគរយទេ។ យើងចង់ធ្វើយ៉ាងណាយុទ្ធនាការចុះឈ្មោះឱ្យប្រជាពលរដ្ឋខ្មែរអាយុ១៨ ឆ្នាំបានចុះឈ្មោះទាំងអស់គ្នាគោលដៅរបស់យើង

គឺពីពេលនេះទៅ ២០០៧-២០០៨ ជាពិសេសក្នុងឆ្នាំ២០០៦នេះ ការចុះឈ្មោះបោះឆ្នោតត្រូវតែបាន១០០ភាគរយតែម្តង គឺថាចលនាគ្រប់គ្នាទោះបីមានការពិបាកយ៉ាងណាក៏ដោយ ហើយមិនគ្រាន់តែ១០០ ភាគរយ ជាបរិមាណទេ គឺជាគុណភាពទៀតសិទ្ធិសំរាំងកុំឱ្យមានការសរសេរឈ្មោះខុស កុំឱ្យបាត់ឈ្មោះ កុំឱ្យមានឈ្មោះហើយតែរកការិយាល័យមិនឃើញ។ ពេលនេះអង្គប្រជុំនិងមានកិត្តិយសបានស្តាប់បង ទី ឈឿន លោកនិងរាយការណ៍នៅយន្តការសរុបនៅក្នុងការរៀបចំការបោះឆ្នោតខេត្តមណ្ឌលគិរីនេះ។

ទី៣ គឺធ្វើយ៉ាងណាឱ្យយន្តការបោះឆ្នោតនៅប្រទេសកម្ពុជា ជាពិសេសឆ្នាំ ២០០៧-២០០៨នេះបានប្រកប ដោយសន្តិសុខ។ យើងលួមដល់ពេលមួយដែលអ្នកឈ្នះឆ្នោត តោងឈ្នះដោយការជឿទុកចិត្តរបស់ប្រជាពលរដ្ឋ មិនមែនឈ្នះបានដោយក្រៅពីវិធីនេះទេ។ យើងជឿថាយើងអាចធ្វើបាន ខ្ញុំបាទទៅកន្លែងផ្សេងៗទៀតមើលឃើញថាការបោះឆ្នោត គឺកាលណាគណបក្សនយោបាយណាធ្វើឱ្យប្រជាពលរដ្ឋទុកចិត្តផ្តល់នៅអ្វីដែលជាការសន្យាជូនដល់ប្រជាពលរដ្ឋ នៅក្បែរប្រជាពលរដ្ឋគឺគេបោះឆ្នោតឱ្យហើយ។ យើងមិនចាំបាច់ប្រើវិធីអ្វីៗផ្សេងទៀតក្រៅពីនេះ ដើម្បីទៅបង្កើតបរិយាកាសភ័យខ្លាចឱ្យប្រជាពលរដ្ឋលោកមកបោះឆ្នោតដោយការភ័យខ្លាចនោះទេ។ ដូច្នេះយើងមានចេតនានិងធ្វើឱ្យបរិយាកាសនៅជុំវិញការបោះឆ្នោតប្រកបដោយសន្តិសុខ និងអហឹង្សា។ អញ្ចឹងហើយបានជាក្រសួងមហាផ្ទៃបានធ្វើការយល់ព្រមជាមួយនិងយន្តការខប់សែលថា ទៅថ្ងៃមុខទៅនៅជុំវិញស្ថានីយបោះឆ្នោតយើងធ្វើយ៉ាងណាលែងឱ្យមានវត្តមានអាជ្ញាធរនៅក្បែរនោះទៀតតាំងពីភូមិ ឃុំ ស្រុក មិនចាំបាច់នៅទីនោះទេ មានតែតំណាង គជប តំណាង PEC តំណាង CEC ដែលជាអាជ្ញាធរនៅជុំវិញការិយាល័យបោះឆ្នោត មិនចាំបាច់មានអាជ្ញាធរទៀតទេ។ ព្រោះមិនចំណេញហើយជះរូបភាពខាតទៅដល់យន្តការបោះឆ្នោតទាំងមូលតែម្តង។ ខេត្តច្រើនណាស់បានទទួលឯកភាពនៅលើសំណើនេះថាចាប់ពីថ្ងៃនេះតទៅមិនឱ្យមានរឿងទាំងអស់នេះទេ។ នេះជាគោលបំណងធំៗហើយខ្ញុំបាទជឿថាយើងអាចធ្វើបាន យើងអាចចូលរួមធ្វើការកសាងជាមួយគ្នាដើម្បីធ្វើយ៉ាងណាជំរុញតួនាទីស្ត្រីឱ្យបានចូលរួម ព្រោះស្ត្រីដែលជាមេឃុំគាត់ពិបាកណាស់។ ខ្ញុំបានទៅជួបស្ត្រីដែលជាមេឃុំគឺពិបាកណាស់ការគាំទ្រពីសហគមន៍ ការគាំទ្រពីសង្គម ការគាំទ្រពីគ្រួសារ។ ជួនកាលពិបាកគាត់សឹងថា ឆ្នាំ២០០៧ នេះមិនឈរទៀតទេ ដូច្នេះយើងធ្វើយ៉ាងណាដើម្បីចលនាជាមួយសង្គមស៊ីវិលគាំទ្រការចូលរួមរបស់ស្ត្រីនៅក្នុងកំរិតមូលដ្ឋាន នៅក្នុងកំរិតឃុំសង្កាត់ឱ្យបាន មិនគ្រាន់តែបានច្រើនទេគឺឱ្យបានមានលក្ខណៈជាគុណភាពតទៅទៀត។ យើងក៏ចលនាចូលរួមដើម្បីឱ្យយុវជន និស្សិត ដែលមានអាយុ១៨ឆ្នាំនិងចូលរួមឱ្យបានច្រើននៅក្នុងយន្តការបោះឆ្នោត ព្រោះពលរដ្ឋដែលមានលក្ខណៈជាពលរដ្ឋពិតប្រាកដ ទាល់តែពលរដ្ឋហ្នឹងបំពេញតួនាទី កាតព្វកិច្ចរបស់ខ្លួនជាពលរដ្ឋតាមរយៈការចូលរួមការបោះឆ្នោត។

លោក ទី ឈឿន ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត

ជាបឋមសូមគោរពកិច្ចប្រជុំខប់សែលប្រ៉ម សូមគោរពលោក Larry Strange ដែលជានាយកនៃ វិទ្យាស្ថាន CDRI និងសូមគោរពលោកឱក សេរី សោភ័ក្តិ ដែលជាទីប្រឹក្សានិងសូមគោរពឯកឧត្តមអភិបាលខេត្ត អភិបាលស្រុក តំណាងគ្រប់ក្រុមប្រឹក្សាឃុំដែលមានវត្តមានព្រឹកនេះ និងសូមគោរពអស់លោក លោកស្រី គ្រប់មន្ទីរ ស្ថាប័ននិងខេត្ត គ្រប់អង្គការក្រៅរដ្ឋាភិបាលប្រចាំខេត្តដែលមានវត្តមានជាទីគោរព។ នៅក្នុងខេត្តយើង យើងដឹងហើយបញ្ហាលក្ខណៈភូមិសាស្ត្រយ៉ាងណានោះ។ ខេត្តមណ្ឌលគិរីមានផ្ទៃដី ១៤ ៩៨២ គីឡូម៉ែត្រក្រឡា ហើយស្ថិតិប្រជាពលរដ្ឋក្នុងឆ្នាំ២០០៥ មាន ៥១ ៦៥៩ នាក់បើយើងគិតជាដង់ស៊ីតេប្រហែលជាជាង ៣នាក់ក្នុងមួយ គីឡូម៉ែត្រក្រឡា ហើយក្នុងនេះមានជនជាតិភាគតិចប្រមាណ៨០-៨៥ភាគរយ។ បើនិយាយពីការលំបាកនៅយើងនេះយើងជាពិសេសលក្ខណៈភូមិសាស្ត្រទីតាំង មិនថាភូមិមិនថាឃុំមិនថាស្រុក គឺពាក់ព័ន្ធនិងវិស័យគមនាគមន៍។ ព្រោះការបោះឆ្នោតកន្លងមកសំខាន់នៅឆ្នាំ ១៩៩៨ និងឆ្នាំ២០០២ ជាការលំបាកខ្លាំងបំផុតក្នុងការបោះឆ្នោតរបស់យើងបញ្ហាលក្ខណៈភូមិសាស្ត្រនេះ។

អញ្ចឹងអស់លោកជាសមាជិកក្រុមប្រឹក្សាឃុំដឹងហើយតាម មូលដ្ឋានទីមួយៗការធ្វើដំណើររបស់យើងមានការឆ្លងហែលទឹក មានការធ្វើដំណើរថ្មើរជើង មានទាំងជិះ មានទាំងមធ្យោបាយផ្សេងៗទៀត ។ កាលឆ្នាំ១៩៩៨ ទំនាស់មួយចំនួនកើតឡើងក្នុងពេលចាប់ដំណើរការរៀបចំការបោះឆ្នោត។ ជំហ៊ានទីមួយដែលលេចធ្លោជាងគេពេលនោះគឺមានអង្គការសង្គមស៊ីវិល ដែលមានបញ្ជីឈ្មោះអ្នកដែលចូលសង្កេតការណ៍រាប់រយនាក់ក្នុងអង្គការនីមួយៗ តែជាក់ស្តែងឈ្មោះនោះមិនមែនជាឈ្មោះអ្នកដែលនៅទីនេះទេមិនដឹងយកមកពីខាងណាទេ ហើយយកបញ្ជីឈ្មោះលក់ធ្វើអាជីវកម្មទៅវិញដោយយកមួយ ១០ដុល្លា ៥០ដុល្លា ទៅតាមការលើកឡើងរបស់គេ និង ឱ្យតួនាទីតំណែងនីមួយៗគឺមួយខែឱ្យពី ៨០ដុល្លា ទៅ ៤០០ឬ៥០០ដុល្លា។ ពេលដែលមានបញ្ហាហើយប្រមូលលុយបានហើយ បុគ្គលនៃអង្គការសង្គមស៊ីវិលរត់បាត់។ អញ្ចឹងធ្វើឱ្យជនរងគ្រោះនៅខេត្តមណ្ឌលគិរីមានការប្តឹងផ្តល់ទៅដល់អាជ្ញាធរដែនដីខេត្តប្តឹងដល់ PEC យើងខ្ញុំរហូតដល់កិច្ចការទាំងអស់យើងខ្ញុំបានបញ្ជូនដល់ គជប ហើយចុងក្រោយ គជប បានសំរេចតែពីរអង្គការទេដែលមកសង្កេតការណ៍ពី៩៨ គឺមានអង្គការខុមហ្វ្រែល អង្គការបណ្ឌិតពុទ្ធា។ ក្រៅពីនេះ គជប បដិសេធនមិនឱ្យចូលក្នុងខេត្តនេះទេ។ ចំណុចទី២ ជាទំនាស់ហូរហែរចាប់ពី ឆ្នាំ១៩៩៨ក៏មាន ឆ្នាំ២០០២ក៏មាន ឆ្នាំ២០០៣ក៏មាន ដោយឡែកតែ២០០៦យើងអត់មានបញ្ហាអ្វីទេ បញ្ហានេះជាការកត់សំគាល់របស់យើងខ្ញុំទេ។ ការងារទាំងអស់ក៏បានដោះស្រាយសំរបសំរួលគ្នាទៅតាមនីតិវិធីនៃច្បាប់បោះឆ្នោតក្នុងការដោះស្រាយតាម CEC តាម PEC និង NEC រហូតដល់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ។ ទំនាស់មួយទៀតនៅក្នុងក្រុមគ្រួសារផ្ទាល់នៅក្នុងបន្ទុកគ្រួសារ ជួនកាលប្តីចូលគណបក្សផ្សេងហើយ ប្រពន្ធចូលគណបក្សផ្សេង ហើយកូនចូលគណបក្សផ្សេងទៀតរហូតដល់មានការលែងលះគ្នាក៏មានការចែកទ្រព្យសម្បត្តិក៏មាន ដោយសារការកាន់គណបក្សផ្សេងគ្នា។ ចំណុចទី៣ បញ្ហាកើតទំនាស់លើកផ្លាកគណបក្សនយោបាយ។ ការលើកផ្លាកនេះមានកើតទំនាស់រវាងគណបក្សនិងអាជ្ញាធររវាងគណបក្សនិងម្ចាស់។ ការលើកផ្លាកដោយមិនបានសូមអនុញ្ញាតពីម្ចាស់ផ្ទះក៏មាន មិនបានសូមច្បាប់ពីអាជ្ញាធរក៏មាន អញ្ចឹងបញ្ហានេះបានដោះស្រាយ សំរបសំរួលគ្នានៅមូលដ្ឋានរួចរាល់ហើយ។ ចំណុចទី៤ គឺខេត្តមណ្ឌលគិរីសំបូរតែជនជាតិ អញ្ចឹងជនជាតិប្រពៃណីពីដើមគឺមាន អាប ធ្មប់ មានការចោទគ្នាចំពោះបញ្ហានេះហើយបញ្ចូលក្នុងនយោបាយគឺចំពេលឃោសនាបោះឆ្នោតតែម្តង។ មួយទៀតជនបទល្មើសផ្នែកព្រហ្មទណ្ឌក៏ដូចជា រដ្ឋប្បវេណី ហើយប្រព្រឹត្តអ្វីខុសផ្សេងៗពីនេះទៀតក៏ដាក់ចូលក្នុងការងារនយោបាយដែរ។ ចំណុចទី៥ គឺបញ្ហាចែកអំណោយមនុស្សធម៌ផ្សេងៗចំការឃោសនាបោះឆ្នោត ដូចជាអំណោយកាកបាតក្រហម កាលឆ្នាំ២០០៣ មានការ ចែកនុំប៉័ងនៅតាមសាលាឃុំ ។ ទំនាស់រវាងអង្គភាពនិងបុគ្គលអង្គភាព ដោយនគរបាលអវត្តមានក្នុងអង្គភាពដោយមិនបានបើកប្រាក់ខែក៏ដាក់ក្នុងនយោបាយបោះឆ្នោតផងដែរ។ មួយទៀតជាទំនាស់ពាក្យសំដីនិងគ្នាក្នុងពេលផឹកស៊ីស្រវឹង រវាងមន្ត្រីរាជការ និងមន្ត្រីរាជការ រវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋពេលដែលស្រវឹងហើយយកការងារទំនាស់ដាក់ក្នុងនយោបាយ នេះជាបញ្ហាមួយដែលយើងត្រូវទប់ស្កាត់។ ការបោះឆ្នោតរយៈកាលកន្លងមកគ្រប់ភ្នាក់ងារគណបក្សនយោបាយ គ្រប់អង្គការក្រៅរដ្ឋាភិបាលដែលបានបញ្ជូនភ្នាក់ងាររបស់ខ្លួនដើម្បីចូលសង្កេតការណ៍ មិនថាការពិនិត្យបញ្ជីឈ្មោះ ចុះឈ្មោះ មិនថាការបោះឆ្នោត គឺមិនបានហ្វឹកហាត់បណ្តុះបណ្តាលភ្នាក់ងារអ្នកដែលចុះទៅនោះ អញ្ចឹងពេលដែលគាត់ចុះទៅសង្កេតការណ៍តាមការិយាល័យបោះឆ្នោតគាត់អត់យល់តួនាទីគាត់សោះ។ ជួនកាលពេលអនុវត្តទៅអង្គុយតុរួមជាមួយ CEC ជាមួយ PSO ដូច្នេះខុសនិងបទបញ្ជានិងនីតិវិធីសំរាប់ការបោះឆ្នោត ក៏ដូចជាភារកិច្ចនៃគណបក្សនយោបាយ ក៏ដូចជា NGOs សំរាប់ធ្វើការសង្កេតការណ៍បោះឆ្នោតនេះ។ ចំណុចខ្វះខាតមួយទៀតខ្ញុំលើកឡើងពី ឆ្នាំ១៩៩៨ រហូតដល់ ឆ្នាំ២០០៦ គឺនិយាយជារួមតែម្តងបញ្ហាប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំ ឡើងទៅត្រូវមានសិទ្ធិបោះឆ្នោត។ នៅខេត្តយើងនេះតាំងពី៩៨ ដល់ ២០០៦ នៅតែជួបការលំបាកជាបន្តបន្ទាប់ បើនិយាយឱ្យចំគ្មានឯកសារបញ្ជាក់សំគាល់អត្តសញ្ញាណតែម្តង។ ឆ្នាំ១៩៩៨ យើងបោះឆ្នោតសំអាងមានប័ណ្ណអ៊ុនតាក់ អញ្ចឹងគាត់ចំលងប័ណ្ណបោះឆ្នោតអ៊ុនតាក់ចូលក្នុងបញ្ជីបោះឆ្នោតដែលរៀបចំដោយ គជប ។ ក្រោយមកទៀតយើងក៏មានបន្ត

បន្ទាប់ដែរ មានសៀវភៅគ្រួសារ ប័ណ្ណសំគាល់គ្រួសារ ខាងនគរបាលមានកាតប៉ូលីស ទាហាន ប៉េអឹមក្នុងបទបញ្ជា នីតិវិធីមានការណែនាំអស់ហើយ។ អ្នកដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតមានឯកសារអ្វីខ្លះជាផ្លូវការរបស់ខ្លួនដែលចេញពីរាជរដ្ឋាភិបាល អញ្ចឹងការអនុវត្តន៍ការពិនិត្យបញ្ជីឈ្មោះ ចុះឈ្មោះ ឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០២ អនុវត្តដោយCEC ។ ចាប់ពី ឆ្នាំ២០០៤ ក្រុមប្រឹក្សាឃុំសង្កាត់ជាអ្នកអនុវត្តដោយមានការប្រគល់អំណាចពី គជប។ សូម្បីតែក្រុមប្រឹក្សាឃុំ និងស្មៀនឃុំដែលអនុវត្តការពិនិត្យបញ្ជីឈ្មោះ ចុះឈ្មោះប្រចាំឆ្នាំ ក៏នៅតែជួបការលំបាកខ្លាំងរឿងបញ្ហាឯកសារដដែល ។ រឿងឯកសារនេះងាយស្រួលក្នុងការចាត់ចែងពិនិត្យបញ្ជីឈ្មោះបើសិនជាមានសំគាល់អត្តសញ្ញាណ ជាការងារស្រួលបំផុត ទាំងការពិនិត្យបញ្ជីឈ្មោះ ចុះឈ្មោះបោះឆ្នោត ទាំងការបោះឆ្នោត។ គជបបានចេញឯកសារមួយសំរាប់ជំនួសប្រជាពលរដ្ឋដែលខ្វះឯកសារ ដើម្បីឱ្យគាត់មានសិទ្ធិពេញលេញក្នុងការបោះឆ្នោតដែរ គឺទំរង់ ១០១៨។ តែដល់យើងត្រូវប្រើ ១០១៨ មានជួបការលំបាកទៀតនៅខេត្តយើងប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតមានបញ្ហារឿងរូបថត។ អញ្ចឹងយើងសួរថាមូលដ្ឋានយើងពី ឆ្នាំ១៩៩៨ ដល់បច្ចុប្បន្ននៅតាមមូលដ្ឋានភូមិ ឃុំ ដាច់ស្រយាលពីខេត្ត សូម្បីតែជិតខេត្តក៏លំបាកដែរបញ្ហារូបថតនេះ គឺពុំមានលទ្ធភាពថតរូប។ នៅក្បែរខេត្តយើងប្រជាពលរដ្ឋអ្នកក្រីក្រពុំមានលទ្ធភាពថត តែអ្នកដាច់ស្រយាលគ្មានកន្លែងថតតែម្តង អញ្ចឹងគឺលំបាក មានបញ្ហាពេលបោះឆ្នោតយកទំរង់ ១០១៨ ទៅបោះឆ្នោត គឺទាមទារឱ្យមានរូបថតអញ្ចឹងលំបាកបញ្ហានេះ។ ពេលគាត់ទៅបោះឆ្នោតខ្លះមានរូបថត ខ្លះអត់ នាំឱ្យមានបញ្ហាទំនាស់គ្នា តើយើងនាំគ្នាដោះស្រាយយ៉ាងម៉េច? សំណូមពរ ផ្តល់អនុសាសន៏ទៅយ៉ាងម៉េចរឿងបញ្ហាការប្រើប្រាស់ទំរង់ ១០១៨។ ចំណុចមួយទៀត គឺបញ្ហាការអនុវត្តក្រុមប្រឹក្សាឃុំ និងស្មៀនឃុំមិនទាន់ស៊ីចង្វាក់គ្នាក្នុងការងារពិនិត្យបញ្ជីឈ្មោះ ចុះឈ្មោះ។ ដោយសារគាត់មានការជាប់រវល់ច្រើននៅមូលដ្ឋានរបស់គាត់ ពេលចុះឈ្មោះម្តងៗគឺជាប់រវល់ផែនការអភិវឌ្ឍន៍ឃុំការប្រជុំក្នុង រដ្ឋបាលមូលដ្ឋានរបស់គាត់មួយៗតាមឃុំសង្កាត់។ អញ្ចឹងការចុះឈ្មោះមិនបានទទួលលទ្ធផលជាប្រសើរទេបានដែរតែមិនបានគ្រប់គ្នាក្នុងការចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតអាយុ ១៨ឆ្នាំ ឡើងទៅ។ ចំណុចខ្វះខាតមួយទៀតថ្មីៗនេះបញ្ហាសំខាន់គឺពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ ដែលការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ គឺបញ្ជីឈ្មោះរបស់ក្រុមប្រឹក្សាឃុំដែលប្រកាសទទួលស្គាល់ពីក្រសួងមហាផ្ទៃ ដល់តែពេលស្រង់បញ្ជីឈ្មោះមកឱ្យខាង PEC គឺខុសសឹងគ្រប់គ្នាប្រហែលជា ៨០ ភាគរយ។ ព្រោះពេលប្រកាសរបស់ក្រសួងមហាផ្ទៃគឺប្រកាសពេលដែលយើងបោះឆ្នោតរួចរាល់បានប្រកាសលទ្ធផលជាផ្លូវការ។ ក្រោយមកទៀតយើងក៏បានធ្វើអត្តសញ្ញាណប័ណ្ណ។ អញ្ចឹងសមាជិកក្រុមប្រឹក្សាឃុំគាត់មិនបានយកឯកសារប្រកាសរបស់ក្រសួងមហាផ្ទៃ បង្ហាញទៅនគរបាលប៉ុស្តិ៍ឃុំ ឬក៏ក្នុងសមាជិកក្រុមប្រឹក្សាឃុំខ្លួនឯងមកចំលងឱ្យបានត្រឹមត្រូវទេ គាត់យកឈ្មោះណាពិរោះហើយដូរ កែតាំងពីថ្ងៃខែឆ្នាំកំណើតក៏មាន។ បញ្ហាការបោះឆ្នោតសមាជិកព្រឹទ្ធសភាកន្លងមកនេះ ភាគច្រើន គឺប្រើប្រាស់យក ១០១៨ មកជំនួសកាតបោះឆ្នោត ដោយសារយកអត្តសញ្ញាណប័ណ្ណដែលគាត់មានជាសៀវភៅ គ្រួសារ ជាឯកសារផ្សេងៗដែលគាត់មានជាផ្លូវការរបស់គាត់មិនត្រឹមត្រូវទៅតាមប្រកាសរបស់ក្រសួងមហាផ្ទៃ ២០០២។ បញ្ហានេះយើងមានការចាប់អារម្មណ៏មែនទែនរឿងបញ្ហាការចុះឈ្មោះនេះ ទាំងអក្ខរាវិរុទ្ធ ទាំងថ្ងៃខែឆ្នាំកំណើត គឺមិនទាមទារឱ្យយ៉ាងណានោះទេ ធ្វើយ៉ាងម៉េចសរសេរអក្សរឱ្យច្បាស់ "ស"ឱ្យពិតជា"ស" "គ"ឱ្យពិតជា"គ" កុំឱ្យច្រឡំគ្នាពិបាកណាស់។ តែនេះបន្ទោសមិនកើតដែរ ព្រោះនៅខេត្តនេះបញ្ហាសំខាន់គឺធនធានមនុស្សក៏រិតយល់ដឹងការរៀនសូត្រនៅខេត្តយើងមានការខ្វះខាតក៏រិតវប្បធម៌តាមមូលដ្ឋាននីមួយៗ។ អញ្ចឹងការងារនេះធ្វើយ៉ាងណាក្នុងសមាជិកក្រុមប្រឹក្សាឃុំ ជាពិសេសស្មៀនឃុំតែម្តង ត្រូវធ្វើយ៉ាងណាការចុះឈ្មោះឱ្យចំតួអក្សរកុំឱ្យច្រឡំ។ មួយទៀតរឿងគណបក្សនយោបាយជាពិសេសការបោះឆ្នោតឆ្នាំ ២០០៣ កាលណោះមានការបូកលទ្ធផល សរុបនៅ CEC ឱ្យភ្នាក់ងារសង្កេតការណ៏រង់ចាំសិនព្រោះការងារមិនទាន់ចប់ចុងចប់ដើមទេ ឱ្យរង់ចាំផ្តល់លទ្ធផលនៅតាមឃុំ បញ្ហាទំរង់ ១១០៥ នេះគឺខ្លះក៏បានរង់ចាំខ្លះទៅអត់ដោយសារធ្វើការងារមិនចប់ចុងចប់ដើម ព្រោះការរាប់សន្លឹកឆ្នោតនេះគឺមិន

កំណត់ពេលទេ លុះត្រាតែការងារនេះចប់ចុងចប់ដើមខ្លះទៅហេវបាយ ខ្លះថាហួសពេលហួសម៉ោងគាត់ទៅបាត់ទៅដល់ពេលចប់ការបំពេញឯកសារនៃលទ្ធផលបោះឆ្នោតនៅតាម CEC គឺខាង CEC គេបានបិទ រហូតដល់រកភ្នាក់ងារបញ្ជូនទៅដល់ទៀត សំរេចទៅវិញទៅមកមកប្តឹងដល់ PEC ទៀត។ អញ្ចឹងកំហុសបង្ករទំនាស់នេះគឺបញ្ហាជាចំណុចខ្វះខាតមួយដែលយើងទាំងអស់គ្នាត្រូវពិចារណាទាំងអស់គ្នា ដើម្បីយើងមានអនុសាសន៍ល្អៗក្នុងការកែសំរួលបញ្ហានេះ ។ ដោយឡែកខាង PEC CEC និង PSO យើងខ្ញុំមានចំណុចខ្វះខាតមួយចំនួនដែរ យើងខ្ញុំផ្ទាល់មន្ត្រីលេខាធិការដ្ឋានដែលជាអ្នកបន្តនិរន្តរភាព គឺការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតសំរេចដោយខ្លួនឯងផ្ទាល់ នេះគឺមិនទាន់ដឹងថាតួនាទី និងសិទ្ធិអំណាចច្បាស់លាស់នៅឡើយដែរ។ បញ្ហានេះខ្ញុំពិនិត្យមើលច្បាប់ក៏ដូចជាក្នុងសេចក្តីណែនាំផ្សេងៗពី គជប គឺមិនទាន់ឃើញថាតួនាទីយើងខ្ញុំជាមន្ត្រីលេខាធិការដ្ឋានមានសិទ្ធិអំណាចជាអ្វីច្បាស់លាស់គឺមិនទាន់មាន។ ហើយកន្លងមកការទទួល និងការដោះស្រាយពាក្យបណ្តឹងផ្សេងៗ យើងខ្ញុំក៏ទទួលស្គាល់ថាការដោះស្រាយមិនទាន់បានត្រឹមត្រូវដោយមូលហេតុថាយើងខ្ញុំខ្វះមន្ត្រីដើម្បីធ្វើការស៊ើបអង្កេតហ្មត់ចត់។ ទី២ បញ្ហាខ្វះជំនាញ ពីព្រោះក្នុងមូលដ្ឋានរបស់យើងនេះ ជាពិសេសសូម្បីនៅ PEC មិនមែនជាជំនាញអ្នកច្បាប់សំរាប់រឿងនេះទេ គឺសុទ្ធតែអ្នកធ្វើការធម្មតាក្នុងមូលដ្ឋាន អញ្ចឹងផ្នែកច្បាប់ជំនាញអ្វីៗគឺយើង យើងរៀនដែរតែពេលវេលាខ្លី។ ការរៀនហ្នឹងមិនក្តាប់ជាប់ឱ្យបាន ១០០ ភាគរយទេរឿងបញ្ហាដោះស្រាយផ្នែកច្បាប់នេះ។ ចំណុចខាង PSO ក៏ដូចជាខាង CEC ដែរ មានចំណុចខ្វះខាតដូចជាការប្រកាសលទ្ធផលដើម្បីបិទផ្សាយនៅពេលបោះឆ្នោត រាប់សន្លឹកឆ្នោតមានការយឺតយ៉ាវ ធ្វើឱ្យមានការមិនពេញចិត្តពីសំណាក់ភ្នាក់ងារគណបក្សនយោបាយ អង្គការសង្គមស៊ីវិលដែល ចុះមកសង្កេតការណ៍មួយចំនួនដែរ។ ដោយសារការភ្លេចណាមួយរបស់គាត់ដែលការងារច្រើន យើងដឹងស្រាប់ហើយការរៀបចំបោះឆ្នោតនេះគឺមានការរៀបចំបែបបទនេះច្រើនណាស់ គឺទៅតាមលំដាប់លំដោយ តាមបទបញ្ជានីតិវិធីនៃឯកសារការរៀបចំការបោះឆ្នោត អញ្ចឹងមានការយឺតយ៉ាវ នេះជាចំណុចខ្វះខាត មិនថា PEC CEC មិនថា PSO កន្លងមកនេះ។ ចំណុចទី៣ធំ អនុសាសន៍ អនុសាសន៍ចំណុចទី១. ទិសដៅយើងគឺការរៀបចំបោះឆ្នោតក្រុមប្រឹក្សាឃុំអាណត្តិទី២ គឺ នេះមិនទាន់ផ្លូវការទេ គ្រាន់តែជំរាបមុនឱ្យហើយប្រហែលជាគេនឹងធ្វើវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ។ បោះឆ្នោតប្រហែលជាថ្ងៃ ០១ ខែ ៤ ឆ្នាំ ២០០៧ មិនមែនថ្ងៃ ០៣ ខែ ២ ឆ្នាំ ២០០៧ ទេ បញ្ហានេះគឺជាសម្ព័ន្ធអនុសាសន៍។ ចំណុចទី២. ឯកសាររបស់ក្រសួងមហាផ្ទៃ ក៏ដូចជាពី គជប បានបញ្ជូនគ្រប់ក្រុមប្រឹក្សាឃុំអស់ហើយ ខ្ញុំបានជូនដំណឹងធ្វើលិខិតលាយលាក់អក្សរទៅតាមលោកអភិបាលស្រុក ហើយជូនដំណឹងទៅលោកអភិបាលខេត្ត ដើម្បីជ្រាបបញ្ហាកិច្ចសហប្រតិបត្តិការក្នុងការងារកែតម្រូវលើសេចក្តីណែនាំរួម លេខ ០១១ របស់ក្រសួងមហាផ្ទៃ និងគជប ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងសេចក្តីណែនាំលេខ ០១៨ របស់ គជប ដែលណែនាំបញ្ហាកែតម្រូវ បញ្ហាការគិតអាយុប្រជាពលរដ្ឋដែលទើបគ្រប់អាយុ ១៨ រហូតមកដល់សព្វថ្ងៃនេះ ថ្ងៃទី ០១ ខែ ០៤ ឆ្នាំ ២០០៧ នេះគឺបានសេចក្តីថាចាប់ ពីមុនខែ ០៤ ឆ្នាំ ១៩៨៩ ដល់ត្រឹមថ្ងៃ ០១ ខែ ០៤ ឆ្នាំ ២០០៧ គឺគាត់គ្រប់អាយុ ១៨ ហើយ។ បញ្ហានេះត្រូវត្រៀមលក្ខណៈនៃការពិនិត្យបញ្ជីឈ្មោះចុះឈ្មោះបោះឆ្នោត ដែលបានផ្តល់ហើយនេះគឺជាពិសេសខាងក្រុមប្រឹក្សាឃុំត្រូវអនុវត្តទៅតាមសេចក្តីណែនាំរួម ក៏ដូចជាសេចក្តីណែនាំរបស់ គជប។ សំណូមពរយើងខ្ញុំគឺសូមឱ្យឯកឧត្តមអភិបាលខេត្ត លោកអភិបាលស្រុក និងស្ថាប័នដែលពាក់ព័ន្ធធ្វើយ៉ាងណាជួយគាំទ្រ និងរំលឹកណែនាំដល់មូលដ្ឋានក្រុមប្រឹក្សាឃុំផ្ទាល់ក្នុងការអនុវត្តន៍ទៅតាមការប្រគល់ប្រតិភូកម្មអំណាចរបស់ គជប ទៅតាមលិខិតលេខ ០៦៦ សជណ របស់ក្រសួងមហាផ្ទៃ ទៅតាមសេចក្តីណែនាំរួម លេខ ០១១ សនណ របស់ក្រសួងមហាផ្ទៃ និង គជប និងតាមសេចក្តីណែនាំ លេខ ៦៨ របស់ គជប ដែលស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋ និងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ជាពិសេសការចុះឈ្មោះឆ្នាំ ២០០៦ របស់យើង ដើម្បីយើងមានមូលដ្ឋានមួយសំរាប់ប៉ាន់ស្មានប្រជាពរដ្ឋទាំងអស់នោះ ដើម្បីឱ្យ គជប រៀបចំដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំអាណត្តិទី២ ឆ្នាំ ២០០៧។ សំណូមពរមួយទៀតអាជ្ញាធរដែនដីគ្រប់

លំដាប់ថ្នាក់ ខេត្ត ភូមិ ឃុំ កងប្រដាប់អាវុធទាំងបីប្រភេទ គ្រប់ស្ថាប័នពាក់ព័ន្ធ គ្រប់គណបក្សនយោបាយ គ្រប់ NGO ក្នុងខេត្តធ្វើយ៉ាងណាការងារពិនិត្យបញ្ជីឈ្មោះ ចុះឈ្មោះក៏ដោយ គឺជួយចូលរួមផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅដល់ជួរប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោត ដើម្បីឱ្យគាត់យល់អំពីសិទ្ធិ និងកាតព្វកិច្ចក្នុងការចូលរួមបោះឆ្នោត។ យើងអត់មានមេក្រូ វិទ្យុផ្សាយឱ្យគាត់ទេ គឺមានតែផ្សព្វផ្សាយតគ្នា ជួយផ្សព្វផ្សាយទៅតាមគ្រួសារ តាមបងប្អូនយើងដែលធ្វើដំណើរទៅមករកស៊ីផ្សេងៗ នៅតាមច្រលងដងអូរដងរណ្តៅគឺជួយផ្សព្វផ្សាយទៅតាមគ្រួសារឱ្យគាត់ដឹងរឿងបញ្ហាហ្នឹង។ តាមរយៈ CDRI សំណូមពរទៅ គជប គឺធ្វើយ៉ាងណាឱ្យ គជប គួរពិនិត្យពិចារណាចំពោះខេត្តយើងខ្ញុំនេះតែម្តង បញ្ហាដែលខ្ញុំនៅតែព្រួយបារម្ភណ៍នៅខាងមុខនេះ គឺបញ្ហាការចុះឈ្មោះខ្លាចអត់មានអត្តសញ្ញាណប័ណ្ណនេះនៅតែប្រើ ១០១៨ ដែលគ្មានរូបថត ព្រោះបញ្ហានៅមូលដ្ឋានយើងខ្ញុំនៅជនបទនេះ គឺមានលទ្ធភាពថតតែគ្មានកន្លែងថត ហើយគាត់មិនងាយទៅធ្វើ ដំណើររាប់រយគីឡូពីភូមិមកខេត្ត ខេត្តមកឃុំដើម្បីទៅថតរូបមិនងាយទេ។ សំណូមពរទៅ គជប ដើម្បីឱ្យគាត់ពិចារណាបន្ថែមចំពោះខេត្តយើងខ្ញុំនេះ ការប្រើទំរង់ ១០១៨ ពុំមានរូបថត តើអាចឱ្យគាត់បោះឆ្នោតបានឬយ៉ាងណា ។ បញ្ហាអត្តសញ្ញាណប័ណ្ណសំរាប់បោះឆ្នោតនេះកើតវិបត្តិខ្លាំងណាស់នៅខេត្តយើងខ្ញុំនេះ ប៉ុន្តែបើសិនជាមានអត្តសញ្ញាណជាតិខ្មែរគឺស្រួលតែម្តង អត់មានបញ្ហាចោទទេ អនុសាសន៍របស់ គជប ដែរគឺបញ្ហាជ្រើសរើសសមាសភាពគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។ ការជ្រើសរើសនេះចាំបាច់ត្រូវតែទាមទារអ្នកមានសមត្ថភាព បទពិសោធន៍ និងសីលធម៌ល្អ។ ការជាក់ស្តែងក្នុងមូលដ្ឋានយើងខ្ញុំកំពុងតែព្រួយបារម្ភណ៍ តិចទៀតបោះឆ្នោតក្រុមប្រឹក្សាឃុំ ខ្ញុំដឹងថាធនធានមនុស្សយ៉ាប់ហើយ ដណ្តើមគ្នាហើយទាំងភ្នាក់ងារគណបក្សនយោបាយសង្កេតការណ៍បោះឆ្នោត ទាំង NGO សង្កេតការណ៍ដែរ ហើយយើងខ្ញុំចុងក្រោយបំផុតការជ្រើសរើស PSO ត្រូវអស់មនុស្សហើយ អញ្ចឹងបញ្ហានេះគឺយ៉ាប់មែនទែនចំពោះអ្នកដែលដាច់ស្រយាល។ អនុសាសន៍មួយទៀត គឺកន្លងមកយើងបានអនុវត្តហើយប៉ុន្តែការងារអនុវត្តនេះត្រូវពង្រឹងបន្តទៀត ទាំងគ្រប់គណបក្សនយោបាយក៏ដូចជា NGO និងស្ថាប័នដែលពាក់ព័ន្ធ។ ពេលបណ្តុះបណ្តាលនៅថ្នាក់ PEC CEC គឺត្រូវតែចូលរួមទាំងអស់គ្នាក្នុងការបណ្តុះបណ្តាលនូវបទបញ្ញត្តិនីតិវិធី និងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងការរៀបចំការបោះឆ្នោត ដើម្បីឱ្យយល់កិច្ចការមិនលាក់លៀមរឿងច្បាប់បោះឆ្នោត រឿងរបៀបរៀបចំឱ្យដឹងនីតិវិធីរៀបចំទាំងអស់គ្នា។ អនុសាសន៍មួយទៀត គឺបញ្ហាគណបក្សនយោបាយពេលឃោសនាបោះឆ្នោត ធ្វើយ៉ាងណាត្រូវគោរពក្រមសីលធម៌សំរាប់គណបក្សនយោបាយ ព្រោះការឃោសនានេះយើងតែងតែមានបញ្ហាទំនាស់ច្រើនក្នុងពេលឃោសនាបោះឆ្នោត។ ជាអនុសាសន៍ គឺធ្វើយ៉ាងណាឱ្យគ្រប់ភ្នាក់ងារគណបក្សនយោបាយក្នុងពេលឃោសនបោះឆ្នោត គឺត្រូវរក្សាក្រមសីលធម៌។ កន្លងមកយើងបានចែកជូនគ្រប់គណបក្សក្នុងខេត្ត ទាំងក្រមសីលធម៌សំរាប់កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ទាំងក្រមសីលធម៌សំរាប់អ្នកសង្កេតការណ៍ជាតិ ។

លោក ឱក សេរី សោភក្តិ

ខ្ញុំបាទសូមអនុញ្ញាតិអញ្ជើញឯកឧត្តម ញ៉ាវ៉ាំងចាន់ ជាអភិបាលរង លោកបានស្តាប់ឮទាំងអស់គ្នាហើយ តែតំណាងអាជ្ញាធរខេត្តយើងនឹងមានកិត្តិយសបានស្តាប់ប្រសាសន៍របស់លោក តើលោកមានប្រតិកម្មយ៉ាងណា?

ឯកឧត្តម ញ៉ាវ៉ាំងចាន់ អភិបាលរងទី៣ ខេត្តមណ្ឌលគិរី

ជាបឋមសូមថ្លែងអំណរគុណដល់លោក Larry Strange នាយកប្រតិបត្តិវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងសូមអរគុណដល់ប្អូន ឱក សេរី សោភក្តិ ដែលជាទីប្រឹក្សានិងជាអ្នកសំរបសំរួលយន្តការខប់សែល និងសូមថ្លែង

អំណរគុណដល់លោកប្រធានលេខាធិការដ្ឋាន។ ទីមួយ ខ្ញុំឯកភាពទាំងអស់តាមបទអន្តរាគមន៏របស់អ្នកសំរបសំរួលយន្តការ COPCEL និងឯកភាពនូវការលើកឡើងរបស់លោកប្រធានលេខាធិការដ្ឋាន។ ជាយោបល់របស់ខ្ញុំមកដល់ពេលនេះការរៀបចំការបោះឆ្នោតនៅកម្ពុជា ដូចជានៅក្នុងខេត្តមណ្ឌលគីរីឃើញថាមានការប្រព្រឹត្តទៅយ៉ាងល្អស្រួល ហើយមានការគាំទ្រពីមតិសាធារណៈ និងអង្គការនានានៅក្នុងកម្ពុជា ក៏ដូចជានៅលើពិភពលោកដែរ។ យើងមានបញ្ហាលំបាកជាច្រើន ជាពិសេសការរៀបចំការបោះឆ្នោតដែលរៀបចំដោយអ៊ុនតាក់មានទាំងភ្លៀង ផ្លូវ អ្នកខ្លះជិះឡាន ជិះយន្តហោះ ខ្លះដើរ ចំពោះការរៀបចំ។ ក្រោយមកទៀតនៅអណត្តិទី២ អណត្តិទី៣ យើងធូរបន្តិចដោយសារមានផ្លូវខ្លះ ចំពោះផលលំបាកដែលបងៗលើកអម្បាញ់មិុញខ្ញុំឯកភាពគឺពិតជាមានការលំបាកច្រើនមែន ហើយលំបាកខាងផ្នែកនយោបាយដំបូងក៏មានការលំបាកច្រើនដែរ តែយើងដោះស្រាយតាមនីតិវិធីមានគណកម្មាការសំរបសំរួលគ្រប់ជាន់ថ្នាក់មានអង្គការខាងក្រៅរដ្ឋាភិបាលជួយ។ ចំពោះគណបក្សនយោបាយនៅពេលដែលដំណើរការជំហ៊ានទី១ ទី២ តែងមាន ប៉ុន្តែសរុបទៅនៅក្នុងខេត្តមណ្ឌលគីរីពុំមានបញ្ហាលេចឡើងធំដុំទេ គឺធម្មតាចេះយោគយល់ បងប្អូន ញាតិ ជាតិតែមួយគ្រប់អណត្តិរហូតដល់អណត្តិចុងក្រោយនេះបោះឆ្នោតព្រឹទ្ធសភា គឺបោះឆ្នោតយ៉ាងល្អមានសភាពស្ងាត់រហូតដល់ទទួលលទ្ធផល។ ប៉ុន្តែទោះបីនៅពេលដំណើរមានការទាស់ទែងគំនិតគ្នារបៀបជាលក្ខណៈគ្រួសារ ឬគណបក្សនយោបាយ ប៉ុន្តែបានការសំរបសំរួលច្រើន។ តាមការប្រមើលមើលជាបន្តទៀតខ្ញុំគិតថាយើងក៏កែមិនកើតដែរចំពោះខេត្តមណ្ឌលគីរី ព្រោះដើមខែ ៤ ជួនកាលមានឆ្នាំខ្លះក៏អត់មានភ្លៀងដែរ ដូចឆ្នាំ ២០០៤-២០០៥ អត់មានភ្លៀង ប៉ុន្តែបើសិនចំខែ ៤ និងមានការពិបាកបើសិនជាភ្លៀង ហើយបើចំយើងកែមិនកើត ហើយទី២ប្រជាជននៅមណ្ឌគីរីនៅឆ្ងាយពីគ្នា ផ្ទៃដីគិតទៅស្មើ និង៤ខេត្ត ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តរតនគីរី ខេត្តមណ្ឌលគីរីផ្ទៃដីធំណាស់ ហើយមនុស្សមិននៅផ្តុំ គឺនៅរាយ។ ទី២ ការចុះឈ្មោះ ការពិនិត្យឈ្មោះ កន្លងមកក៏ជាការខិតខំរបស់លេខាធិការដ្ឋានដែលជាអ្នករៀបចំ អ្នកណែនាំដាស់ តឿនឃើញថាគាត់ហត់មែន ព្រោះកិច្ចការនេះដូចគាត់លើកអញ្ជឹង សូម្បីតែក្រុមប្រឹក្សាឃុំក៏អញ្ជឹងដែរ។ ការរៀបចំដាក់ឈ្មោះអញ្ជឹង ដល់ពេលគាត់នឹកឃើញ គាត់ដាក់ឈ្មោះផ្សេង ឬខ្វះអក្ខរាវិរុទ្ធ កែទៅកែមកហត់ណាស់។ ចុះទម្រាំប្រជាជនទៀតមើលទៅដូចជាមិនដឹងអ្នកណានិយាយកើត។ ការស្នាក់នៅរស់នៅរបស់គាត់ ពិសេសដូចជាបងប្អូនដែលស៊ីឈ្នួលគេមិនដឹងបានចុះឈ្មោះបោះឆ្នោតឬអត់ ដូចជានៅពូជ្រៃ នៅកែវសីមា។ ខ្ញុំអាជ្ញាធរពិតប្រាកដមែនប៉ុន្តែមិនដឹងថាគេមកអង្កាល់ ទៅវិញអង្កាល់ មានតែជូនដំណឹងតាមលេខាធិការដ្ឋានគេប្រាប់មកអាជ្ញាធរ សូមប្រកាសជូនដំណឹងគ្រប់ប្រជាពលរដ្ឋទាំងអស់ ឱ្យចុះឈ្មោះ ពិនិត្យឈ្មោះ ធ្វើលិខិតហើយប្រាប់ភូមិ ឃុំ ស្រុក ប្រមើលមើលថាអ្នកខ្លះមិនដឹងថាយ៉ាងម៉េចផង ត្រឹមប្រកាសថ្ងៃនេះ ខែនេះមើលឈ្មោះ ពិនិត្យឈ្មោះគ្រប់អាយុចុះឈ្មោះ គេមិនមកមើល។ ជាក់ស្តែងដូចការងាររដ្ឋបាលមូលដ្ឋានការចុះអត្រានុកូលដ្ឋាន គាត់ថាមិនដឹងគេចុះឈ្មោះគេធ្វើម៉េច ឥឡូវមកដល់ពេលនេះមិនទាន់ទទួលទូរលេខប៉ុន្មានផងដែលយុទ្ធនាការចល័តចុះឈ្មោះអត្រានុកូលដ្ឋាន ហើយឃុំសង្កាត់គាត់ថាការងារច្រើនណាស់ធ្វើមិនបាន ធ្វើមិនកើត។ បញ្ជាក់ហើយបញ្ជាក់ទៀតថាមេឃុំនៅប៊ុយរ៉ូចាត់ក្រុមប្រឹក្សាឃុំមួយឱ្យសហការណ៏ជាមួយក្រុមចល័តឱ្យចុះ ចុះមកហើយគេសរសេរផ្តិតមេដៃត្រឹមត្រូវហើយមកស៊ីញ៉េនៅប៊ុយរ៉ូសាលាឃុំ គាត់ថាគាត់មានការងារច្រើនណាស់។ សូមអំពាវនាវអង្គការក្រៅរដ្ឋាភិបាលឱ្យជួយតាមភូមិ ឃុំ ឱ្យជួយនិយាយពីរឿងឈ្មោះ ការគ្រប់អាយុ ការចុះអត្រានុកូលដ្ឋាន។ នៅឃុំខ្ញុំខ្លះថាច្រើនអង្គការហៅទៅនេះទៅនោះហើយមិនបានចុះឈ្មោះ អត់បានធ្វើអត្រានុកូលដ្ឋាន ហើយបើសិនអស់អត្រានុកូលដ្ឋានយើងមិនមែនអ្នកសញ្ជាតិខ្មែរទេ ជាជនអន្តោប្រវេសន៏វិញ។ ហើយការផ្លាស់ប្តូរទីលំនៅទៀតសូមជួយខ្ញុំផង សូមជួយឱ្យការរស់នៅរបស់គាត់ត្រឹមត្រូវ ការផ្ទេរមកសូមឱ្យចុះឈ្មោះ ឧទាហរណ៏អ្នកភូមិក្រែកនៅមេមត់ អ្នកកំពង់ចាម បងប្អូនចាម បងប្អូនខ្មែរ ទៅនេះក៏មិនពិនិត្យឈ្មោះ ទៅនោះក៏មិនពិនិត្យឈ្មោះ មិនត្រូវគេហៅថាផ្ទេរឬស្នាក់នៅមិនត្រូវរឿងម៉េចនិងមើលឈ្មោះកើត។

លោក ឌិក សេរី សោភក្តិ៍

ខ្ញុំបាទសូមជំរាបថា សូមមេត្តាយកពេលដែលយើងសំរាកដើម្បីគិតពិចារណាអំពីប្រសាសន៍របស់បង ទី ឈឿន និងអភិបាលរងខេត្តនៅជុំវិញបញ្ហាទាំងប៉ុន្មានដែលយើងបានជួបតំណាងគណបក្សនយោបាយ តំណាងអង្គការសង្គមស៊ីវិល និងមន្ទីរនានា យើងអាចលើកជាបញ្ហាបន្តទៀត អ្វីដែលយើងមើលឃើញជាបញ្ហា ប៉ុន្តែការដែលសំខាន់នៅពេលត្រឡប់មកវិញតើអ្វីខ្លះដែលយើងអាចដោះស្រាយរួមគ្នាបាន។ ខ្ញុំបាទបានកត់ទាំងអស់នូវអ្វីដែលជាចំណុចបញ្ហា ហើយខ្ញុំបាទកំពុងតែគិតថាដល់ពេលត្រឡប់ទៅវិញតើអ្វីខ្លះដែលអាចធ្វើការជាមួយនិងក្រសួងមហាផ្ទៃ ជាមួយនិងខាង គជប ឯកឧត្តម អ៊ឹម សួស្តី និងឯកឧត្តម ទេព នីថា និងធ្វើការជាមួយ UNDP ដើម្បីកន្លែងណា ដែលលំបាកតើយើងជួយយ៉ាងម៉េចបាន ដូចជាបញ្ហារូបថត បញ្ហាដែលបងប្អូននៅពាសវាលពាសការជុំវិញបញ្ហាផ្លូវដែលយើងពិបាក ឯកឧត្តមអភិបាលលោកលើក គឺថានៅខេត្តឯទៀត១មិនទាន់ភ្លៀងទេ ប៉ុន្តែនៅមណ្ឌលគិរីមាន ភ្លៀងហើយ។ ដូច្នេះចំណុចទាំងប៉ុន្មានដែលខ្ញុំកត់នេះកំពុងតែពិចារណាថាជួយយ៉ាងម៉េចបាន ហើយដល់ពេលត្រឡប់ទៅវិញ និងធ្វើការដើម្បីរកដំណោះស្រាយជួយខាងអាជ្ញាធរខេត្ត និងខាងបង PEC និងគ្នាយើងទាំងអស់គ្នា។ មួយទៀតខ្ញុំបាទសូមថ្លែងអំណរគុណដល់ខាងបាលមូលដ្ឋានដែលលោកធ្វើការគ្រប់ខេត្តទាំងអស់ ជាពិសេសខេត្ត នេះដែលមានការលំបាក លោកជួយចែកចាយឯកសារទាំងប៉ុន្មានដែល CDRI បានបោះឡើងដើម្បីឱ្យបានដល់គ្រប់ភូមិ ឃុំ សង្កាត់។

លោក ឌិក សេរី សោភក្តិ៍

យើងបានស្តាប់នូវប្រសាសន៍របស់ឯកឧត្តមអភិបាលរងខេត្ត និងប្រសាសន៍របស់លោកប្រធាន PEC ខេត្ត ហើយ ដូច្នេះឥឡូវនេះខ្ញុំសូមជូនវេទិកានេះទៅលោកស្រី អស់លោក បងវីរៈសេនីឯកខាងប៉ូលីសអញ្ជើញមានប្រសាសន៍ ។

លោក មាស សុជាតិ តំណាងក្រុមការងារគណបក្សសមរង្ស៊ីប្រចាំស្រុកកែវសីមា

មានយោបល់ទាក់ទងនឹងប្រធាន PEC លោកទី ឈឿន ដែលបានមានយោបល់ថាក្រុមការងារខ្លះដែលរៀបសន្លឹកឆ្នោត មិនទាន់ចប់តែឆ្លៀតពេលទៅមុនពេលបញ្ចប់ ប៉ុន្តែចំពោះកន្លែងខ្ញុំនៅគឺស្រុកកែវសីមាបញ្ជូនសន្លឹកឆ្នោតមកទាំងអស់នៅក្នុងការិយាល័យដែលត្រូវរាប់សន្លឹកឆ្នោតនោះ មិនទាន់បានរាប់សន្លឹកឆ្នោតផង តំណាង CEC ហើយបានមករៀបចំគោលការណ៍នេះជាថ្មីដើម្បីបញ្ចប់។ លោក ទី ឈឿន គាត់ និយាយថាកាលណារៀបសន្លឹកឆ្នោត មិនទាន់ចប់ផង តំណាងគណបក្សដែលចុះបានដើរចោលកន្លែងប៉ុន្តែកន្លែងខ្ញុំអត់ទេ ហើយប្រធាន PEC ដល់ពេលសួរដេញដោល ថាក្រុមការងារ ដល់អញ្ចឹងខ្ញុំមិនដឹងនិយាយ យ៉ាងម៉េចតាមដំណើរ ទៅ។

លោក ឌិក សេរី សោភក្តិ៍

សូមអរគុណបងប្រុសតំណាងខាងគណបក្សសមរង្ស៊ីអម្បាញ់មិញ ដែលលោកមានប្រសាសន៍ជាចំណុចផ្ទាល់ហើយខ្លី។ ខ្ញុំចង់បញ្ជាក់បន្តិចថាគួរតែយើងបានស្តាប់សំដីរបស់លោកស្រី បងស្រី ឬមួយនាងកញ្ញាដែលចូលរួមនៅទីនេះឱ្យមានសំឡេង ព្រោះអ្វីដែលមានប្រសាសន៍ទៅគឺយើងកត់ទាំងអស់ អត់មានបាត់មួយពាក្យទេ ហើយអ្នកដែលអានមានឋានៈធំ១ណាស់ តាំងពីមហាក្សត្រ អង្គការអន្តរជាតិ រដ្ឋាភិបាល ថ្នាក់ដឹកនាំហូរហែរ ហើយខេត្តឯ ទៀត១ក៏នឹងចែករំលែកជាមួយដែរ។ ដូច្នេះនេះជាឱកាសហើយ ដែលយើងគួរតែមានប្រសាសន៍ ។

លោក ហូ ហ៊ួរ ក្រុមការងារគណបក្សសមរង្ស៊ី ឃុំមនោរម្យ

គណបក្សសមរង្ស៊ីមានការខ្វះខាតកន្លងមកតាំងពីឆ្នាំ ២០០២ ដូចជាសម្ភារៈ ហិរញ្ញវត្ថុក៏មានការខ្វះខាតដែរ ព្រោះធ្វើការកន្លងមកអត់ស្មើភាពគ្នា។ ដូចជា ឆ្នាំ២០០២ ខ្ញុំបានតែ ២០២ សំឡេងទេក្នុងការបោះឆ្នោតឃុំ ដល់តែមកដំណាក់កាលឆ្នាំ ២០០៣ បោះឆ្នោតរដ្ឋសភា ក៏ខ្ញុំឃើញថាមានការខ្វះចន្លោះខ្លះតាមការពិនិត្យមើលរបស់ ខ្ញុំ គណបក្សសមរង្ស៊ីមានការខ្វះខាតហិរញ្ញវត្ថុជាចាំបាច់ ខ្វះខាតខាងសម្ភារៈក៏ចាំបាច់ដែរដូចជាវិទ្យុទាកទងគេឃាត់មិនឱ្យនិយាយ។

លោក ឱក សេរី សោភក្តិ៍

ខ្ញុំសូមអនុញ្ញាតិលោកអ៊ំ បញ្ហាណាដែលជាការខ្វះខាតនៅផ្ទៃក្នុងរបស់គណបក្សមិនទាក់ទងនឹងអ្នកដទៃទេ គឺជាបញ្ហាផ្ទៃក្នុងគណបក្សរបស់លោកអ៊ំផ្ទាល់តែម្តង ដូច្នេះយើងចៀសវាងបញ្ហាណាដែលជាបញ្ហាផ្ទៃក្នុងរបស់គណបក្ស។ បើសិនលោកអ៊ំជាសមាជិកក្រុមប្រឹក្សាឃុំ ទាក់ទងទៅនឹងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ លោកអ៊ំមានប្រសាសន៍ចុះយើងដោះស្រាយរួមជាមួយគ្នា ប៉ុន្តែបញ្ហាដែលថារឿងហិរញ្ញវត្ថុរបស់បក្សមិនទាក់ទងអ្នកដទៃទេ ទាល់តែលោកអ៊ំលើកនៅក្នុងរង្វង់គណបក្សផ្ទាល់តែម្តង។

លោក ហូ ហ៊ួរ ក្រុមការងារគណបក្សសមរង្ស៊ី ឃុំមនោរម្យ

នេះខ្ញុំលើកបុគ្គលក្នុងគណបក្សសមរង្ស៊ី មានការខ្វះខាតពេលឃោសនា មានគ្នាតិចកំលាំងខ្សោយធ្វើយ៉ាងម៉េចក៏មិនឈ្នះគណបក្សដទៃដែរ។ អញ្ចឹងបានជាខ្ញុំសូមសំណូមពរកន្លងមកមាន ដូចបង ទី ឈឿន លោកលើកឡើង ហើយមានការបាញ់បោះមានការចែកនំប៉័ងហូរហែរ ។ ប៉ុន្តែខ្លួនខ្ញុំពេលឃោសនាដូចឃើញស្រាប់ហើយ កំលាំងខ្ញុំតិចមានតែម៉ូតូ៣គ្រឿងទេ ធ្វើបាន ១០០០ ជាងដែរចេញពីបាតដៃទទេ បក្សខាងលើអត់មានជួយផ្តល់អ្វីធំដុំទេ នេះខ្ញុំរាយការណ៍ត្រង់ ព្រោះកំលាំងរបស់ខ្ញុំមានតិចអត់ហ៊ានចេញមុខអ្វីធំដុំទេ ព្រោះខ្លាចគេប្រើពាក្យសម្តីនិយាយអញ្ចេះអញ្ចុះ ម្លោះហើយប្រជាពលរដ្ឋចេះតែខ្លាចរើសអើង។

អ្នកស្រី សេង ខេម នាយិកាសាលាបឋមសិក្សា

ជាបឋមសូមគោរពអភិបាលខេត្តរង សូមគោរពតំណាងអង្គការខប់សែលប្រ៉ម ព្រមទាំងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។ ពាក់ព័ន្ធទៅនឹងមតិរបស់លោកទី១ ដែលគាត់បានបំភ្លឺឡើងក្នុងបញ្ហាការចូលសង្កេតការណ៍នៅក្នុងការបោះឆ្នោត។ ឆ្នាំ ២០០៣ បោះឆ្នោតតំណាងរាស្ត្រ ឆ្នាំ១៩៩៨ ឆ្នាំ២០០២ នាងខ្ញុំបានចុះផ្ទាល់នៅក្នុងឃុំកែវសីមាតែម្តង គឺការខ្វះខាតចំពោះមុខដូចលោកប្រធាន PEC លើក។ ជួនកាលគាត់បោះឆ្នោតចប់ហើយ សុំទោសខ្ញុំសូមនិយាយឱ្យចំតែម្តង គណបក្សខ្លះដឹងថាចាញ់អត់នៅទទួលទំរង់ ១០១៥ ទេដល់ពេលក្រោយមកមានបញ្ហាផ្ទាល់ថាយើងមិនបានចែកជូន។ ដូច្នេះនៅអណត្តិក្រោយ១ទៀតសូមសំណូមពរថាឱ្យការបោះឆ្នោតរួចរាល់ចាំលោកដែលជាអ្នកសង្កេតការណ៍គណបក្សនយោបាយចាំអញ្ជើញចេញ ដើម្បីឱ្យដឹងស្ថិតិត្រឹមត្រូវទាំងអស់គ្នា ។ ទី២ មានសំណូមពរមួយទៅដល់ក្រុមប្រឹក្សាឃុំ ពីបញ្ហាការចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ ២០០៧ នេះបើមិនរៀបចំបញ្ហាការចុះឈ្មោះឱ្យបានត្រឹមត្រូវទេគឺមានផលលំបាកច្រើន។ ពីព្រោះចំពោះមុខការបោះឆ្នោតព្រឹទ្ធសភា កន្លងទៅគឺមានផលលំបាកក្នុងការចុះឈ្មោះដែរ។ ហើយក្នុងនោះទៀតក្នុងការស្រង់ឈ្មោះ ខាង PEC បានផ្តល់ជូន ទំរង់ ១០២៤ ដើម្បីឱ្យឃុំផ្សព្វផ្សាយទៅដល់ភូមិ ជ្រើសរើសឈ្មោះពីអាយុ ១៨ ឆ្នាំឡើង និងអ្នកដែលមិនទាន់ចុះឈ្មោះបោះឆ្នោត ដូច្នេះក្នុងក្រុមប្រឹក្សាឃុំអាចមានសមាជិក ៥ នាក់ ជាពិសេសស្មៀនឃុំតែម្តងសុំជួយជំរុញយ៉ាងណាដើម្បីប្រមូលឈ្មោះអាយុ១៨ឡើង និងអ្នក

ដែលមិនទាន់ចុះឈ្មោះគឺទំរង់ ១០២៤ នេះខ្ញុំផ្តល់ជូនតាំងពីចប់បោះ ឆ្នោតព្រឹទ្ធសភាពីដើមខែ ២ ហើយនៅពេលដែលយើងចុះឈ្មោះក្នុងខែ ១០ មានរយៈពេល តែ ២០ ថ្ងៃទេ ៥ ថ្ងៃនៅឃុំ ១០ ថ្ងៃនៅតាមការិយាល័យចល័ត ៥ ថ្ងៃមកដល់កន្លែងឃុំវិញ។ ដូច្នេះសុំប្រមូលស្ថិតិ និងព័ត៌មានចុះឈ្មោះបោះឆ្នោតនេះឱ្យបានចូលទំរង់ ១០២២ វិញឱ្យបានជាស្ថាពរ។

លោកស្រី លឹម គឹមឡែម នាយរងអគ្គលេខាធិការសាលាខេត្តមណ្ឌលគីរី

សូមគោរពអភិបាលខេត្តរងមណ្ឌលគីរី និងសូមគោរពលោក លោកស្រីមកតាមមូលដ្ឋាន អាជ្ញាធរទាំងអស់។ ខ្ញុំតំណាងឱ្យគណបក្សប្រជាជនសូមមានយោបល់ និងសំណូមពរខ្លះចំពោះអង្គប្រជុំ។ តាមស្តាប់របាយការណ៍របស់ឯកឧត្តមអភិបាលខេត្ត ក៏ដូចជាគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត ខ្ញុំសូមឯកភាពទាំងស្រុងនឹងការរៀបចំការបោះឆ្នោត ការងាយស្រួលនិងការលំបាកដែលបានលើកកន្លងមក។ តាមការចុះផ្ទាល់របស់នាងខ្ញុំ ដែលចូលរួមនៅក្នុងការងារបោះឆ្នោត ពីឆ្នាំ ១៩៩៨ និងអណត្តិទីពីរដែលបោះឆ្នោតព្រឹទ្ធសភានេះឃើញថាមានជួបការលំបាកដូចគាត់បានលើកឡើងអញ្ចឹងដែរ។ លំបាកទី១ រឿងមធ្យោបាយធ្វើដំណើរដែលយើងចុះទៅតាមមូលដ្ឋានមួយៗ នៅខេត្តមណ្ឌលគីរីឆ្ងាយណាស់ ដូចជានៅស្រុកសែនមនោរម្យមានឃុំរមនា នៅស្រែជាដើមឆ្ងាយពីទីរួម ស្រុកអញ្ចឹងការធ្វើដំណើរនៅក្នុងខែវស្សាដែលយើងត្រូវការងារបោះឆ្នោត គោលដៅរបស់រាជរដ្ឋាភិបាលគឺជួបការលំបាកណាស់ ជួនកាលមានទឹកជន់លិចម៉ូតូ ហែលទឹកខ្លះលង់ទឹកខ្លះហែលផុត។ ហើយលំបាកមួយទៀត ដែលយើងទៅដល់កន្លែងទីតាំងការិយាល័យបោះឆ្នោត ហើយប្រជាជនមកអត់បានជុំគ្នាទៅតាមពេលវេលាកំណត់ ព្រោះគាត់នៅឆ្ងាយ ខ្លះជិះដំរី ខ្លះកង់ ខ្លះរទេះ ដូច្នេះនាំឱ្យមានការលំបាក។ ការជួបលំបាកនេះគាត់បានលើកឡើងហើយ គ្រាន់តែខ្ញុំសំណូមពរថា ទី១ សូមឱ្យថ្នាក់លើ ថ្នាក់ជាតិជួយគិតគូរយ៉ាងម៉េចដូចជាអ្នកធ្វើការងារបោះឆ្នោតបំរើនៅក្នុងហ្នឹង ខ្លះគ្នាអត់មានមធ្យោបាយទៅទេផ្លូវឆ្ងាយ ជិះម៉ូតូមួយ ២-៣ នាក់ ឧបគ្គារួមទាំងអីវ៉ាន់ផងរបស់ហូបចុកផង។ ធ្វើយ៉ាងម៉េចដោះស្រាយមធ្យោបាយធ្វើដំណើរតាមលទ្ធភាព ខេត្តមណ្ឌលគីរី ខុសប្លែកពីខេត្តដទៃទៀត។ សំណូមពរទី២ សូមឱ្យថ្នាក់ជាតិជួយឧបត្ថម្ភប្រាក់ដល់អ្នកបំរើការងារបោះឆ្នោតឱ្យមានកំរិតខ្ពស់ពីលើហ្នឹងបន្តិច ដើម្បីជួយលើកទឹកចិត្តដល់អ្នកធ្វើការងារបោះឆ្នោត។ សំណូមពរទី៣ សូមឱ្យផ្តល់អាទិភាពដល់នារីឱ្យបានចូលរួមនៅក្នុងការងារបោះឆ្នោត ទាំងនៅខេត្តមណ្ឌលគីរី ក៏ដូចជាទូទាំងប្រទេសដែរ គឺឱ្យមានអាទិភាពខ្ពស់ឱ្យគាត់ចូលរួមកិច្ចការងារនៅក្នុងសង្គមការរៀបចំបោះឆ្នោតយើងវិវត្តន៍យ៉ាងម៉េច? ខ្ញុំមិនមែនទាមទារយកសិទ្ធិពេញលេញមក ខាងនារីទេ ធ្វើយ៉ាងម៉េចឱ្យស្មើគ្នា។

លោក ឱក សេរី សោភក្តិ

អរគុណបងស្រីជាពិសេសចំណុចចុងក្រោយ។ នៅខាង UNDP និងអង្គការផ្តល់ជំនួយឯទៀតៗដែលខ្ញុំធ្វើជាទីប្រឹក្សា យើងបានជំរុញកម្មវិធីលើកតំកើនតួនាទីស្ត្រីនៅក្នុងយន្តការបោះឆ្នោតយើងកំពុងតែរៀបចំទាំងកញ្ចប់ថវិកា គឺនិន្នាការទំនោរទៅក្នុងរឿងហ្នឹងច្រើនណាស់ ហើយខ្ញុំបានចុះទៅមូលដ្ឋានផ្ទាល់នៅខេត្តទាំង ១៣ ហើយខ្ញុំគំរោងចុះទៅទៀតទាល់តែគ្រប់ ២៤ ខេត្ត ហើយមួយខេត្តចុះដល់ទៅ ២ ដងដែរ គឺយើងបានជួបនឹងមេឃុំជាស្ត្រី គាត់មានសេចក្តីក្លាហានច្រើនណាស់ តែការលំបាករបស់គាត់ ខ្ញុំឯកភាពជាមួយបងស្រី គាត់លំបាកជាងបុរសខ្លាំងក្នុងឋានៈជាអ្នកគ្រប់គ្រងឃុំសង្កាត់។ នេះជាកិច្ចការមួយដែលយើងត្រូវតែធ្វើជាអាទិភាព ហើយយើងកំពុងតែធ្វើការជាមួយនឹងគណបក្សធំៗទាំងបី និងគណបក្សផ្សេងទៀតដើម្បីធ្វើយ៉ាងណាដាក់បេក្ខជនស្ត្រីនៅក្នុងលំដាប់មួយដែលអាចជាប់បានកុំឱ្យដាក់យកតែល្អមើល។ ធ្វើយ៉ាងណាឱ្យស្ត្រីដែលអាចជាប់បានរហូតដល់ ៣០-៣៥ % នៅលើបញ្ជីឈ្មោះបេក្ខជនគណបក្សនយោបាយ។ យើងក៏កំពុងតែធ្វើការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលស្ត្រី ដូចជា អង្គការចំរើនស្ត្រី អង្គការ GAD

អង្គការ Silaka និងអង្គការផ្សេងៗទៀត។ CDRIក៏មានធ្វើការរៀបចំនៅក្នុងរឿងអស់ ដើម្បីជំរុញតួនាទីស្ត្រីនៅក្នុងនយោបាយមូលដ្ឋាននៅក្រុមប្រឹក្សាឃុំសង្កាត់ឱ្យបានច្រើន ព្រោះគាត់នៅគៀកជាមួយនឹងប្រជាពលរដ្ឋ។ ដូច្នេះអ្វីដែលបងស្រីមានប្រសាសន៍ទាំងប៉ុន្មាន ខ្ញុំសូមថ្លែងអំណរគុណ ហើយសូមឱ្យទទួលដឹងថាជាការកង្វល់នៅក្នុងខេត្តឯទៀតក៏មានយោបល់ដូចបងស្រី ហើយយើងខ្ញុំជាអ្នករៀបចំកម្មវិធីខប់សែលប្រ៉មនេះក៏ យើងផ្តល់អាទិភាពខ្ពស់នៅក្នុងបញ្ហាស្ត្រីដែរ។

វិរៈសេនីយ៍ទោ សំ សំអាត ស្នងការរងខេត្ត

តាងនាមខ្ញុំវិរៈសេនីយទោស្នងការរង និងជាប្រធានសេនាធិការនៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគីរី។ ខ្ញុំសូមលើកឡើងពីតារាង "ក២" និង "ក៤"។ ការងារ"ក២" ជាការស្នាក់នៅបណ្តោះអាសន្នដោយប៉ុស្តិ៍រដ្ឋបាលរបស់ខ្ញុំនៅមានកំរិត អ្នកមកស្នាក់នៅបណ្តោះអាសន្នជួនកាលគាត់អត់បានសហការណ៍ជាមួយប៉ុស្តិ៍រដ្ឋបាលទេ គាត់ចេះតែមកស្នាក់នៅ ហើយប៉ុស្តិ៍រដ្ឋបាលខ្ញុំមិនបានចុះទេ។ ឥឡូវនេះកម្មករសំណង់កាន់តែច្រើនគាត់មិនបានទៅដេកផ្ទះសំណាក់ទេ ខ្ញុំមិននិយាយពីផ្ទះសំណាក់ទេនិយាយពីផ្ទះឯកជន អញ្ចឹងគាត់អត់បានសហការណ៍ជាមួយប៉ុស្តិ៍រដ្ឋបាលទេ ពីដើមផ្លូវពិបាកយើងថាពិបាកហើយ តែឥឡូវផ្លូវស្រួលគាត់កាន់តែមក។ នេះជាបញ្ហាស្នាក់នៅបណ្តោះអាសន្ន អញ្ចឹងសូមឱ្យជួយសហការណ៍ជាមួយប៉ុស្តិ៍រដ្ឋបាល ហើយខ្ញុំនឹងជំរុញប៉ុស្តិ៍រដ្ឋបាលឱ្យសហការណ៍ជាមួយម្ចាស់ផ្ទះដើម្បីធ្វើការងារនេះ។ បន្ថែមទៀតនេះគាត់ទៅរៀននៅស្ទឹងត្រែងហើយមកវិញនឹងបញ្ចុះ ឥឡូវប៉ុស្តិ៍រដ្ឋបាល មាន២ ឬ៣ នាក់ តាមពិតក្របខ័ណ្ឌត្រូវមាន ៩នាក់ បើមិនបានគ្រប់ក៏បាន៩នាក់ដែរនេះជាមុខសញ្ញាមួយដែលខ្ញុំកំពុងតែភ័យព្រួយ។ រឿង"ក២"នេះលើកមុនខាងការងារប៉ុស្តិ៍រដ្ឋបាលយើងខ្ញុំ លោកអធិការគាត់មានកំរិតដែរ ដោយគាត់សរសេរមានលុប ឥឡូវនេះអ្នកដែលលុបសូមអញ្ជើញយកទៅដូរ និងចុះលេខពីមុនអត់ទាន់ចុះលេខទេ នេះខ្ញុំសូមប្រកាសជាឱឡារិកថាសូមអញ្ជើញយកទៅដូរហើយចុះលេខ ដើម្បីឱ្យមានក្របខ័ណ្ឌត្រឹមត្រូវ។ ពីមុនគាត់សរសេរមានលុបគឺទុកជាមោឃៈហើយ។ ខ្ញុំសូមទោសដោយមានការខ្វះខាតដែរខាងរដ្ឋបាលអធិការនៅមានកំរិតគាត់សរសេរលុបអញ្ចឹងឥឡូវអត់ឱ្យលុបទេយកទៅដូរថ្មី ដូរថ្មីហើយចុះលេខទៀត។ ខ្ញុំឮថាមានយកលុយយកកាក់ នេះខ្ញុំមិនដឹងយ៉ាងម៉េចទេ ប៉ុន្តែគោលការណ៍គឺគ្មានទេ។

លោក ឱក សេរី សោភ័ក្តិ៍

ក្នុងការដែលបានស្តាប់ប្រសាសន៍អញ្ចឹងហើយ ដែលនាំឱ្យយើងមានជំនឿលើយន្តការបែប COPCELPROM នេះ ព្រោះអ្វីដែលលោកវិរៈសេនីយ៍ទោ និងបងៗដែលប្រសាសន៍គឺនិងបានអានដោយស្ថាប័នខ្ពស់ៗណាស់ ព្រមទាំងខេត្ត និងក្រុងផ្សេងៗទៀត។ យើងយល់ថាបញ្ហាដែលចាក់ស្រេះមិនមែនយើងអាចដោះស្រាយភ្លាមបានភ្លាមទេ ប៉ុន្តែមានឆន្ទះនយោបាយនៅក្នុងការឈានទៅរកដំណោះស្រាយ។ នៅខេត្តផ្សេងៗទៀតក៏ដូចគ្នាដែរការដែលមន្ត្រីថ្នាក់ក្រោមមានប្រសាសន៍ អញ្ចឹងដល់ធ្វើទៅលំបាកបានជារុញទៅដល់ក្រសួងមហាផ្ទៃរហូតដល់ឯកឧត្តម ស ខេង លោកក៏ថ្លែងជាសាធារណៈដែរ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏លោកថ្លែងជាសាធារណៈដែរ នៅក្នុងការធ្វើយ៉ាងណាឱ្យយន្តការបោះឆ្នោតបានកាន់តែល្អប្រសើរឡើងបន្តិចម្តងៗ។

រិទ្ធិ សុផុន ប្រធានរដ្ឋបាល គណបក្សហ៊្វុនស៊ិនប៉ិច

ខ្ញុំសូមសំណូមពរគណបក្សទីមួយៗគ្មានមធ្យោបាយដឹកទេពេលបោះឆ្នោត គណបក្សខ្លះមានមធ្យោបាយដឹកដូចឯកឧត្តមលើកអញ្ចឹងដឹកមកបោះឆ្នោតឱ្យខ្លួនឯងបណ្តោយ។ សំណូមពរធ្វើយ៉ាងណាបោះឆ្នោតអាណត្តិលើកក្រោយកុំឱ្យមាន។ សូមឱ្យអង្គការ

ជួយដឹកមក ព្រោះប្រជាជននៅឆ្ងាយ ខ្លះនៅតាមស្រុកមួយៗដល់ពេលបោះឆ្នោតផលវិបាករឿងភ្លៀងផង ដូច្នេះគ្នាអត់បានមកទេ ទៅជំរុញគាត់យ៉ាងម៉េច។ ហើយម្យ៉ាងទៀតទៅចុះឈ្មោះហើយយកលុយទៀត ចាស់ៗនាំអ្នកគ្រប់អាយុឱ្យចុះឈ្មោះ ស្មៀនឃុំថាទាល់តែឱ្យលុយបានចុះឱ្យ ដូច្នេះបាត់សំឡេងរឿងដែលដល់អាយុហើយគេមិនចុះឱ្យ។ រឿងមួយទៀតទៅធ្វើអត្តសញ្ញាណប័ណ្ណសំគាល់ជនជាតិក៏ទារលុយដែរ បើអត់មានលុយគេអត់ធ្វើឱ្យ។ ដូច្នេះសូមសំណូមឱ្យជួយកែសំរួលរឿងនេះឱ្យបានស្រួលដល់ប្រជាពលរដ្ឋនៅខេត្តមណ្ឌលគីរី ព្រោះប្រជាជនចំរុះគ្នាមានភាគតិច ភាគច្រើន ។ មួយទៀតរឿងគ្រួសារ ដែលចូលគណបក្សផ្សេងគ្នាសូមកុំឱ្យមានការឈ្លោះប្រកែកគ្នា គេចូលគណបក្សណា បោះឆ្នោតឱ្យគណបក្សណា គេ មានសិទ្ធិ។

លោក ឱក សេរី សោភក្តិ

ខ្ញុំសូមថ្លែងអំណរគុណដល់លោកសុផុន ដែលលោកមានប្រសាសន៍មួយម៉ាត់នេះគឺជាសំដីមានអត្ថន័យណាស់ យើងចូលគណបក្សណាក៏ចូលទៅក្នុងគ្រួសារតែមួយប្តីប្រពន្ធចូលគណបក្សណាក៏ចូលទៅសូមកុំលែងគ្នា ព្រោះរឿងជីវិតគ្រួសារផ្សេង រឿងគណបក្សផ្សេង។ ដូច្នេះបើសិនយើងអាចនៅជាមួយគ្នាបានក្នុងលក្ខណ:នេះ ជាការជឿនលឿនមួយខ្លាំងណាស់សំរាប់ប្រជាពលរដ្ឋខ្មែរយើង។ ខ្ញុំក៏សូមបួងសួងសូមឱ្យសំដីដែលលោកអំុនិយាយសូមឱ្យក្លាយជាការពិត នៅក្នុងដួងចិត្តរបស់ប្រជាពលរដ្ឋយើងតាមគ្រួសារនីមួយៗ។

លោក សៅ សារិម អភិបាលស្រុកអូរាំង

ជាបឋមខ្ញុំបាទសូមគោរពឯកឧត្តម អភិបាលរងខេត្ត ខាងវិទ្យាស្ថាន CDRI និងលោកស្រី អស់លោកទាំងអស់។ ខ្ញុំបាទសូមឯកភាពទៅនិងចំណុចជាច្រើន ដែលលោកប្រធានលេខាធិការគណកម្មាការខេត្តមណ្ឌលគីរី ដែលបានលើកឡើងពីបញ្ហាអម្បាញ់មិញនេះ។ ក្នុងនេះខ្ញុំបានរកឃើញបញ្ហាដែលបង្កើតឱ្យមានទំនាស់ ក្រោយការបោះឆ្នោត។ ខ្ញុំសូមអនុញ្ញាតិលើកយកចំណុចសំខាន់ៗពាក់ព័ន្ធទៅនិងការងារនៅក្នុងមណ្ឌលគីរី ហើយក៏ជារឿងជាក់ស្តែងផងដែរ :

-ទី១ កើតចេញពីជនកេញចំណេញ។ ព្រោះច្បាប់មាន បទបញ្ជាផ្ទៃក្នុងមាន ហើយក្រមសីលធមិបោះឆ្នោតក៏មានយើងបានដឹងទាំងអស់គ្នាហើយ ក៏ប៉ុន្តែមិនត្រូវបានយកចំណុចទាំងអស់នេះទៅអនុវត្ត និងមិនបានយកទៅធ្វើជាគោលសំរាប់ការងារឃោសនាការងារធ្វើសកម្មភាពរបស់ខ្លួននៅមូលដ្ឋាន។ ទាក់ទងនិងបញ្ហាដែលលោកប្រធានលើកឡើង ការចែកអំណោយនៅពេលដែលឃោសនានេះ នៅក្នុងច្បាប់បានហាមក្នុងក្រមសីលធមិបានហាមហេតុអីយើងជៀសវាងមិនរួចក្នុងរយ:ពេលនៃការឃោសនាដែលមានរយ:ពេលខ្លីសោះ នេះក៏ជាការបង្កឱ្យកើតមានបញ្ហាទំនាស់មួយដែរ។

-ទី២ បញ្ហាភូមិសាស្ត្រ គឺភូមិនៅតាមភូមិ ឃុំ ស្រុក នីមួយៗនៅដាច់ស្រយាលណាស់ រហូតដល់សព្វថ្ងៃអត់មានអជ្ញាធរណាគ្រប់គ្រងបានទេ ហើយក៏មិនទាន់មានអ្នកណាមួយរៀបចំថា តើឱ្យមានការគ្រប់គ្រងដោយវិធីណា។ ឧទាហរណ៍ ភូមិ "ក" កាលណាយើងមិនបានទៅចុះឈ្មោះបោះឆ្នោតឬក៏គាត់មិនបានមកបោះឆ្នោតទាន់ពេលទេ គឺឱកាសមួយរបស់គណបក្សនយោបាយលោកកេងចំណេញ។ គាត់ថាដោយសារគណបក្សខ្ញុំ ដោយសារសមាជិកនៅភូមិនេះគាំទ្រខ្ញុំ បានគេមិនទៅចុះឈ្មោះឱ្យ ឬក៏គេមិនឱ្យដំណឹងទៅដល់គាត់បានគាត់មកបោះឆ្នោតអត់ទាន់ពេលវេលា។ មួយទៀតបញ្ហាឯកសារ ដូចបានលើកឡើងនីតិវិធីនៃការបោះឆ្នោត។ ឧទាហរណ៍ជាក់ស្តែងនៅពេលនេះអ្នកដែលមានសិទ្ធិអំណាចក្នុងការសំរេច ឬក្នុងការឱ្យឱវាទទៅថ្នាក់ក្រោម គឺអ្នកនោះកំរចូលរួមប្រជុំណាស់។ បានន័យថាអត់ដឹងតែម្តង ដូចការផ្សព្វផ្សាយថ្ងៃនេះបានន័យថាអ្នកណាមកគឺអ្នកនោះដឹង អ្នកណាអត់មកគឺអ្នកនោះអត់ដឹង ។ អញ្ចឹង

អ្នកដែលមកចូលរួមភាគតិចណាស់ ជាអ្នកដែលមានសិទ្ធិអំណាចក្នុងការពាំនាំអត្ថន័យថ្ងៃនេះយកទៅផ្សព្វផ្សាយដល់អ្នកក្រោម ជាពិសេសសមាជិកក្រុមប្រឹក្សាឃុំ។ ខេត្តមណ្ឌលគីរីជួនកាលថ្ងៃដែលគេធ្វើសកម្មភាពទើបបានឯកសារមកដល់ ដល់ពេលឯកសារមកដល់ហើយយើងផ្សព្វផ្សាយទៅតាមមូលដ្ឋានទៀត អាចកេងចំណេញទៅគណបក្សណាដែលមានគ្នាគាត់ គាត់ធ្វើលឿន ហើយគណបក្សណាដែលមិនមែនគ្នាគាត់ធ្វើយឺតទៅរឿងដែលអាចចោទប្រកាន់គ្នាដោយសារថាមិនមែនគណបក្សរបស់ខ្លួន តាមការពិតរឿងដោយសារបញ្ហាមធ្យោបាយទេបើយើងសង្កត់ធ្ងន់។

-ទី៣ បញ្ហានីតិវិធីបោះឆ្នោត មិនមែនចេះតែគណកម្មាការបោះឆ្នោតទេ គឺត្រូវចេះទាំងអស់គ្នា ទើបយើងជៀសវាងទំនាស់បាន។ ខ្ញុំមើលឃើញខុសច្រើនជាងគេ គឺគណកម្មាការបោះឆ្នោត និងមន្ត្រីរាជការដែលលោកជាអ្នកកាន់អំណាច។ ដូចខាងភ្នាក់ងារគណបក្សនយោបាយទៅអង្គុយជាមួយគណកម្មាការបោះឆ្នោតដែរ។ នេះបានន័យថាគាត់មិនយល់ពីនីតិវិធី ហើយនីតិវិធីមិនបានពន្យល់ គឺមិនចេះដោយសាររឿងខាងថ្នាក់ដឹកនាំខាងលើលោកមិនយកចិត្តទុកដាក់។ ឧទាហរណ៍រឿងគណបក្សនយោបាយគាត់មិនបានបង្រៀនសកម្មជនរបស់គាត់ឱ្យច្បាស់លាស់ ក៏គាត់ទៅធ្វើខុសនីតិវិធីនាំឱ្យបង្កើតមានទំនាស់ប្តឹងផ្តល់គ្នា នាំឱ្យមានបញ្ហាដល់ក្រោយការបោះឆ្នោត។ ក្នុងនីតិវិធីនេះផង ដែរគណកម្មាការខ្លួនឯង បើសិនជាខាងអ្នកសង្កេតការនយោបាយលោកមិនច្បាស់យើងគួរណាស់រកពេលពន្យល់គាត់ ប៉ុន្តែឆ្លៀតដល់ពេលគាត់មិនច្បាស់ហើយគឺកេងចំណេញតែម្តង ព្រោះដោយគេមិនដឹងថាអ្វីខុសអ្វីត្រូវនេះក៏ជាបញ្ហាដែលនាំឱ្យមានទំនាស់ដែរ។

-ទី៤. រឿងការចុះឈ្មោះមិនបានគ្រប់ បញ្ហាលុយឋិតនៅក្នុងកំហុសឆ្គងរបស់ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំតែម្តងនេះជាកំហុសមួយដែលកើតឡើងនៅក្នុងរឿងហ្នឹង។ ភ្ជាប់ទៅក្នុងរឿងនេះ ខ្ញុំសូមសំណូមពរទាក់ទិនទៅ នឹងបញ្ហាចុះឈ្មោះបោះឆ្នោតនេះសូមឱ្យលេខាធិការបោះឆ្នោតខេត្តមេត្តាប្រឹងប្រែងឱ្យច្រើនជាងហ្នឹង បើទំលាក់រឿងហ្នឹងឱ្យតែក្រុមប្រឹក្សាឃុំ ទំនាស់អត់ចប់ទេ ព្រោះគាត់បានលើកឡើងខ្លួនគាត់ហើយ គាត់ថាការងារច្រើនណាស់គាត់ធ្វើមិនអស់ទេ។ តាមដែលខ្ញុំមើលគឺធ្វើមិនអស់មែនក្នុងនាមខ្ញុំជាអាជ្ញាធរ ខ្ញុំមើលទៅឃើញធ្វើមិនអស់ទេ ហេតុដែលខ្ញុំធ្វើមិនអស់ព្រោះបើយើងមើលទៅឥឡូវមាន ២៤ មន្ទីរ សរុបនឹងខេត្តមួយទៀត ២៥ គាត់ទំលាក់រឿងទាំងអស់ទៅឱ្យក្រុមប្រឹក្សាឃុំ ជាអ្នកទទួលបូកទៅនិងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនច្រើនទៀតដែលគាត់ចុះទៅក្រុមប្រឹក្សាឃុំ ហើយថែមទាំងរដ្ឋបាលមូលដ្ឋាន ដែលគេហៅថាវិមជ្ឈការទៀត បានន័យថាឃុំគាត់ទទួល ការងារច្រើន រហូតដល់អត់ធ្វើតែម្តង ដល់តែធ្វើច្រើនពេកធ្វើមិនអស់ឈប់ធ្វើ ទាំងអស់តែម្តង។ នេះដែលខ្ញុំមើលទៅឃើញបញ្ហាដែលនាំមានទំនាស់ដល់ពេលគាត់ទៅចុះឈ្មោះបោះឆ្នោតអត់បានគាត់ចោទថា ដោយសារគណបក្សផ្សេងបានឃុំមិនចុះឈ្មោះឱ្យវានាំឱ្យប្តឹងគ្នាដោយសាររឿងហ្នឹងនាំឱ្យមានទំនាស់ដែរ។ មួយទៀតខ្ញុំមើលទៅឃើញរឿងសំណូមពររបស់ខាងលេខាធិការគណៈកម្មការបោះឆ្នោត ខ្ញុំសូមឯកភាពទាំងស្រុងទាក់ទិនទៅរឿងបញ្ហាសុំការអនុញ្ញាតិឱ្យប្រើប្រាស់លិខិតបញ្ជាក់មានសិទ្ធិទៅបោះឆ្នោត ព្រោះកាលណាយើងយកទៅតាមល័ក្ខខ័ណ្ឌដូចខេត្តផ្សេងៗ ខ្ញុំជឿថាមណ្ឌលគីរីធ្វើទៅអត់រួចទេ ព្រោះគាត់គ្មានទាំងលុយមកថតរូបសំរាប់ទៅបិទ ដើម្បីធ្វើប័ណ្ណបោះឆ្នោតកើត អញ្ចឹងខ្ញុំស្នើសុំថាឱ្យត្រឹមលិខិតបញ្ជាក់ដោយមិនបាច់មានរូបថតទៅបោះឆ្នោតបាន។

ទីបញ្ចប់ខ្ញុំសូមសំណូមពរដោយទទូចទាក់ទិនទៅនឹងគណបក្សនយោបាយ សូមអនុញ្ញាតិមេត្តាលើកយកបញ្ហាក្រមសីលធម៌នៃការបោះឆ្នោតយកមកអនុវត្តទាំងអស់គ្នា បើមិនអញ្ចឹងទេយើងមិនអាចបំបាត់ទំនាស់ក្រោយពីការបោះឆ្នោតបានទេ។ អ្វីដែលខ្ញុំលើកឡើងនេះខ្ញុំសូមអធ្យាស្រ័យផងដែរ គឺថាខ្ញុំស្រែកឃ្លានទៅនឹងការដែល យើងបោះឆ្នោតចំណាយលុយអស់ច្រើន យើងគួរតែសោកស្តាយក្រោយពីការបោះឆ្នោត យើងមិនដែលបានសុខគ្រប់អណត្តិ។

លោក ឱក សេរីសោភក្តិ

កាលដែលខ្ញុំបាទស្រឡាញ់ ហើយចូលចិត្តយន្តការខប់សែលនេះ ជាពិសេសខប់សែលប្រ៊ម ដោយសារបានឮសំដីអញ្ចឹង ឮសំដីដែលនៅជុំវិញតុបានមានប្រសាសន៍ តាមបងអាជ្ញាធរស្រុកគាត់អត្ថាធិប្បាយមកបញ្ហាមានប្រហែល១គ្នានៅខេត្តឯទៀត១ ជាពិសេសនៅពេលដែលគាត់មានប្រសាសន៍ថាក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ ដល់តែការងារគាត់ច្រើនពេកគឺគាត់អត់ធ្វើតែម្តង។ ហើយខ្ញុំទៅមើលកិច្ចការគាត់ផ្ទាល់គឺគាត់ចម្លងដោយដៃយ៉ាងសម្បើមណាស់ រួចដល់តែស្ថាប័នច្រើនពេកទៅគាត់អត់ធ្វើគាត់បែកគំនិតធ្វើតែកន្លែងណាដែលបានលុយ ហើយរឿងនៅក៏រិតបុគ្គលក៏រិតរឿងបញ្ហាថវិកាយកទៅបំភ្លៃទៅជារឿងនយោបាយតែម្តង។ ដូច្នេះអ្វីដែលបងអភិបាលស្រុកមានប្រសាសន៍មកអម្បាញ់មិញគឺខ្ញុំឯកភាពណាស់ ហើយក៏ទទួលស្គាល់ជាមួយទាំងអស់គ្នាដែរថា ការខ្វះខាតមានអញ្ចឹងមែនដូចដែលបងស្រី បងប្រុស និងលោកវីរៈសេនីយទោមានប្រសាសន៍អញ្ចឹង សុទ្ធតែជាការដែលយើងអាចឈានទៅរកដំណោះស្រាយបាននៅក្នុងរឿងអស់នេះ មិនមែនអត់ទៅតែបញ្ហាភូមិសាស្ត្រនៅមណ្ឌលគីរីនេះ ខ្ញុំបានស្តាប់មួយព្រឹកមកមុននឹងមកមណ្ឌលគីរីនេះដឹង តែឥឡូវដឹងកាន់តែច្បាស់ថែមទៀតថាមិនធម្មតាទេ។ ខែ ០៧ នៅពេលដែលយើងបោះឆ្នោតជាខែភ្លៀង នៅមណ្ឌលគីរីមិនដូចកន្លែងឯទៀត១ទេ បើខែ ០៤ ក៏ដូចជាភ្លៀងដែរ។ ដូច្នេះការដឹកជញ្ជូនប្រជាពលរដ្ឋមកបោះឆ្នោត ហើយកុំថាដល់បោះឆ្នោតមកចុះឈ្មោះបោះឆ្នោតក៏លំបាកដែរ។ ខ្ញុំបាទសំណូមពរ ហើយនឹងទៅជួបក្រសួងមហាផ្ទៃ និងគណៈកម្មការជាតិរៀបចំការបោះឆ្នោតគឺនៅពេលចុះឈ្មោះបោះឆ្នោតឱ្យធ្វើយ៉ាងណាប្រើប្រាស់ ០៩ ខែដែលជាពេលវេលានៃការ ចុះឈ្មោះបោះឆ្នោតត្រៀមដោយក្រុមប្រឹក្សាឃុំសង្កាត់និងស្មៀនឃុំ គឺយើងប្រើប្រាស់ ០៩ ខែហ្នឹង ឱ្យបានល្អជាទីបំផុត ជាពិសេសឆ្នាំនេះជាឆ្នាំសំខាន់ណាស់ក្នុងការប្រើប្រាស់ ០៩ ខែត្រៀមហ្នឹង។ បញ្ហារឿងអត្តសញ្ញាណប័ណ្ណយើងបានឯកភាពព្រមគ្នាហើយ ហើយក្រសួងមហាផ្ទៃ ឯកឧត្តម ស ខេង លោកក៏បានថ្លែងការណ៍ដែរ គឺទាំងអស់គ្នាយល់ថាបញ្ហានេះជាបញ្ហាគន្លឹះ យើងនឹងខំប្រឹងដោះស្រាយតទៅទៀតជាមួយគ្នា។

លោកស្រី ហ៊ូ មួយអ៊ាន ជំទប់ទី២ ឃុំស្ពានមានជ័យ

នាងខ្ញុំសូមលើកពីបញ្ហាអត្តសញ្ញាណប័ណ្ណភ្ជាប់ជាមួយលោកខាងនគរបាល។ ផ្នែកអត្តសញ្ញាណប័ណ្ណចូលធ្វើនៅឃុំនាងខ្ញុំទើបតែបាន ២-៣ ថ្ងៃហើយក៏ដកកំលាំងទៅធ្វើនៅឃុំផ្សេងទៀត ក្នុងនោះប្រជាជនរបស់នាងខ្ញុំដែលមានអាយុ ១៨ ឆ្នាំមានច្រើនហើយធ្វើអត់ទាន់។ អ្នកខ្លះនៅឆ្ងាយគាត់ទៅរៀននៅភ្នំពេញគាត់ត្រឡប់មកវិញ ដោយគាត់ឮថានៅក្នុងឃុំនេះធ្វើអត្តសញ្ញាប័ណ្ណ ដល់ពេលមកដល់នគរបាលគាត់ដកកំលាំងចេញទៅអញ្ចឹងអ្នកដែលអាយុ ១៨ ឆ្នាំត្រូវអាក់ខាន។ សំណូមពរសូមឱ្យខាងបងនគរបាលជួយសំរួលបន្ថែមថ្ងៃបន្តទៀត ដើម្បីងាយស្រួលក្នុងការដែលយើងចុះឈ្មោះបោះឆ្នោត។ ទី២. នាងខ្ញុំសូមភ្ជាប់ជាមួយបង ទី ឈឿន បងមានប្រសាសន៍ថាឯកសារបញ្ជូនទៅក្រុមប្រឹក្សាឃុំអស់ហើយនៅក្នុងការចុះឈ្មោះបោះឆ្នោត ២០០៧ នេះ ចំណែកនាងខ្ញុំដែលជាក្រុមប្រឹក្សាឃុំដូចជាអត់ទាន់ដឹង បើនិយាយឱ្យចំទៅនេះជាផ្ទៃក្នុងរបស់ខ្ញុំមិនមែនថាយើងលើកមួយដាក់មួយល្អមួយអាក្រក់មួយមិនមែនទេ តែបើយើងគិតឱ្យដល់ការងាររួមនៅក្នុងឃុំការងារអ្វីក៏ដោយក៏យើងត្រូវតែដឹងទាំងអស់គ្នា ព្រោះយើងជាក្រុមប្រឹក្សាឃុំការងារអ្វីក៏យើងត្រូវដឹងទាំងអស់គ្នា អញ្ចឹងរាល់លិខិតស្នាមទាំងឡាយណា ដែលមានដាក់ចូលនៅក្នុងឃុំ យើងត្រូវតែដឹងឮទាំងអស់គ្នាដើម្បីចៀសវាងថាមួយដឹងមួយមិនដឹង។ មួយទៀតរឿងបញ្ហាបោះឆ្នោតនៅឆ្នាំ ២០០៧ ខាងមុខនេះខាងខ្ញុំក៏ដូចជាបងស្រីខាងខេត្តមានប្រសាសន៍ដែរថា សំណូមពរសូមឱ្យស្ត្រីឈរលំដាប់លេខរៀងដែលអាចជាប់បាន បើនាងខ្ញុំបានដឹងខ្លះ១គឺលំដាប់លេខរៀងទី១ ឬទី២ នោះបានយើងមានប្រសិទ្ធភាព នៅពេលដែលបោះឆ្នោតហើយយើងនឹងបានជាប់។ ក្នុងនោះយើងយកស្ត្រីដែរតែមិនមែនយកក្នុងនាមជាស្ត្រី ចេះតែយកទេយើងត្រូវរើសសមត្ថភាព យើងត្រូវរើសស្ត្រីនោះដែលមានទំនុកចិត្តខ្លួនឯង ថាខ្លួនអាចនឹងធ្វើបាននោះចាំយកមក អញ្ចឹងបើ

ឱ្យតែស្ត្រីយកមកដោយអត់មានសមត្ថភាពផងតើយើងធ្វើការយ៉ាងម៉េច? ដូចបងខាងអភិបាលរង ស្រុកលោកមានប្រសាសន៍ហើយថា ការងាររបស់ឃុំបច្ចុប្បន្ននេះច្រើនណាស់ រាល់ថ្ងៃធ្វើ ការច្រើនហើយធ្វើអត់អស់ទៀត។ មួយទៀតរឿងគណបក្សនយោបាយ ខ្ញុំសូម ជម្រាបអស់លោក លោកស្រីទាំងអស់ឱ្យបានជ្រាបថានេះជារឿងផ្ទៃក្នុងរបស់ខ្ញុំ ហើយក៏ជារឿងផ្ទៃក្នុងរបស់គ្រួសារខ្ញុំដែរ វាចាកប្រធានបទ ប៉ុន្តែក៏ដូចជាក្នុងប្រធានបទដែរ ក្នុងគ្រួសាររបស់នាងខ្ញុំកាន់គណបក្សខុសគ្នា ម៉ែ ឪ កូនបក្សផ្សេង ប៉ុន្តែសូមឱ្យបងប្អូនទាំងអស់យល់ និងជ្រាបថាយើងជាខ្មែរដូចគ្នា ហើយខ្ញុំបក្សផ្សេង ប្តីបក្សផ្សេង កូនបក្សផ្សេងតែក្រុម គ្រួសាររបស់នាងខ្ញុំអត់មានប្រកាន់គណបក្សនយោបាយណាទេ ព្រោះយើងយល់ថាយើងជាខ្មែរដូចគ្នា បើយើងឈ្លោះគ្នាតើយើងអភិវឌ្ឍន៍សង្គមប្រទេសជាតិរបស់យើងយ៉ាងម៉េច? ដូច្នេះសំណូមពរឱ្យទាំងអស់ទាំងថ្នាក់លើ ថ្នាក់ក្រោម ថ្នាក់ជាតិ ថ្នាក់អង្គការអ្វីក៏ដោយជួយសំរួលថា យើងត្រូវតែព្រួតដៃគ្នា សាមគ្គីគ្នា នោះទើបប្រទេសយើងរស់ បើយើងមិនសាមគ្គីគ្នាទេប្រទេសយើងនឹងមិនរស់ទេ យើងកុំប្រកាន់គ្នាយើងធ្វើការជាមួយគ្នារាល់ថ្ងៃ។

លោក សំ សំអាត ស្នងការរងខេត្ត

សូមឆ្លើយនឹងមតិបងស្រីអម្បាញ់មិុញថា ការងារអត្តសញ្ញាប័ណ្ណប្រជាពលរដ្ឋដែលយើងទៅធ្វើនេះយើង មានផែនការ។ ឧទាហរណ៍ នៅឃុំសែនមនោរម្យ ខ្ញុំឃើញជាក់ស្តែងផ្ទាល់ ជួនកាលមួយថ្ងៃធ្វើបាន ៣ នាក់ អញ្ចឹង សុំក្រុមប្រឹក្សាឃុំជួយជំរុញឱ្យការងារធ្វើអត្តសញ្ញាណ ប័ណ្ណឱ្យគាត់មកឱ្យបានសស្រាក់សស្រាំ ហើយភ្នាក់ងារយើងខ្ញុំ នឹងដាក់ផែនការទៀតដើម្បីការងារហ្នឹង ព្រោះការងារហ្នឹងក្រសួងមហាផ្ទៃបានថា ថ្ងៃ ៣០ ខែ ១២ ត្រូវធ្វើ ឱ្យហើយស្រេចចំពោះអ្នកដែលមានអាយុ ១៨ ឆ្នាំ ឡើង។ អញ្ចឹងជួយជំរុញផង មិនមែនខាងសមត្ថកិច្ចយើងខ្ញុំធ្វើទៅបានទេ ទាល់តែយើងសហការធ្វើការគ្នាបានធ្វើទៅបាន ដូច្នេះសូមជួយសហការផងតែខ្ញុំផ្ទាល់ទៅមិនរួចទេ។ នៅទីនេះ ២០% ជាជនជាតិខ្មែរ ៨០% ជាជនជាតិភាគតិចដែលមាន ជាង១០ ជនជាតិឯណោះ។ ខែនេះគាត់ធ្វើចំការផងព្រលឹមឡើងគាត់ទៅបាត់ ហើយយើងចុះទៅធ្វើយ៉ាងម៉េច? គាត់មានសម្តីថាពីដើមមកមិនដែលមានអ្នកណាធ្វើអញ្ចឹងផងមិនដែលទៅឯណាផងហ្នឹង។ អញ្ចឹងកតព្វកិច្ចនេះខ្វះខាតពីខាងយើងខ្ញុំផង ខ្វះខាតពីខាងក្រុមប្រឹក្សាឃុំផង ត្រូវជួយពន្យល់គាត់ថាការធ្វើអត្តសញ្ញាប័ណ្ណប្រជាពលរដ្ឋខ្មែរមានកត្តាសំខាន់ណាស់យើងយល់យើងដឹងហើយ តែគាត់អត់យល់គាត់ថាធ្វើ ដើម្បីអីទេបើគាត់មិនដែលទៅណាផងភ្នំពេញក៏មិនដែលទៅផង។ បងប្រធាន PEC ខេត្តក៏គាត់ដឹងដែរគាត់ថាពិបាកឱ្យតែគាត់ធ្វើចំការព្រលឹមឡើងគាត់ចេញទៅបាត់ហើយ ឱ្យសមត្ថកិច្ចទៅធ្វើយ៉ាងម៉េច? ឃាត់គេមិនឱ្យទៅចំការយ៉ាងម៉េចបើជាអាជីពរបស់គេ អញ្ចឹងបានថាសូមក្រុមប្រឹក្សាឃុំជួយសហការដើម្បីឱ្យការងារបានដើរទៅមុខ ហើយឱ្យមានប្រសិទ្ធភាពក្នុង ថ្ងៃ ៣០ ខែធ្នូ ២០០៦ ។ បើតាមក្រឹតក្រមឥឡូវនេះលែងមានលិខិតស្នាមអ្វីទៀតហើយ ទាល់តែមានអត្តសញ្ញាណប័ណ្ណបានយើងបោះឆ្នោតបានអញ្ចឹងខ្ញុំត្រូវជំរុញ ខ្ញុំមានផែនការ ហើយខាងក្រុមខ្ញុំនៅមានកំរិតកុំព្យូទ័រជួនកាលខូចពេលដែលខូច ធ្វើនៅទីនេះមិនបានទេទាល់ទៅភ្នំពេញដែលត្រូវចំណាយពេលអស់កន្លះខែទើបបានមកវិញព្រោះត្រូវការមធ្យោបាយ និងថវិកា។

លោក ឯម វាសនា មន្ត្រីកម្មវិធី អង្គការ Vigilance

កន្លងទៅខ្ញុំសង្កេតឃើញថាពេលបោះឆ្នោតតែងតែមានការដឹកជញ្ជូនប្រជាពលរដ្ឋដោយរថយន្ត ចំណុចនេះដែលខ្ញុំសំណូមពរថានៅក្នុងអង្គប្រជុំគួរតែមានវិធានការយ៉ាងណា? ជាសំណួរហាក់ដូចជាចាកប្រធានបន្តិច ខ្ញុំចង់ដឹងថានៅពេលដែលមានការគំរាម

កំហែងដល់សកម្មជនគណបក្សនយោបាយនៅតាមមូលដ្ឋាន ជាពិសេសស្ត្រី តើយើងគួរដោះស្រាយបញ្ហា និងបង្ការបញ្ហានេះកុំឱ្យកើតមានយ៉ាងណា?

លោក មាស សុជាតិ តំណាងក្រុមការងារគណបក្សសមរង្ស៊ីប្រចាំស្រុកកែវសីមា

សូមគោរពក្រុមការងារធ្វើអត្តសញ្ញាណប័ណ្ណ ខ្ញុំមានឆ្ងល់បន្តិចចាប់ពីអាយុ ១៨ ឆ្នាំបានធ្វើបានចុះបើសិនជាការដែលអាយុ ៣០-៤០ឆ្នាំ អាចធ្វើបានដែរឬអត់ ហើយតើអត្តសញ្ញាណប័ណ្ណចុះធ្វើគ្រប់ឃុំ ស្រុកដែរឬអត់ ព្រោះនៅស្រុកកែវសីមាដូចជាអត់ទាន់មានឮទេ។ ហើយគាត់ថាដាច់ខែ ១២ ឈប់ធ្វើ ចុះបើខាងខ្ញុំមិនទាន់ផង ក្រែងមានបញ្ហាទៅថ្ងៃក្រោយ។

លោក សម សំអាត ស្នងការរងខេត្ត

សូមឆ្លើយទៅនឹងស្រុកកែវសីមា ក្រុមការងារខ្ញុំចុះទៅធ្វើតែកុំព្យូទ័រខូចអញ្ចឹងដកមកវិញសិនចាំមកធ្វើបន្តទៀត នៅស្រែខ្លុងខ្ញុំធ្វើហើយ។ គេមានផែនការរបស់គេ ដោយសារកុំព្យូទ័រខូចខ្ញុំយកទៅធ្វើនៅភ្នំពេញ អញ្ចឹងត្រូវដកកំលាំងមកសិនកុំឱ្យនៅយូរ នៅពេលដែលបានមកចាំធ្វើបន្តទៀត ធ្វើគ្រប់តែម្តងអត់មានឱ្យខ្វះទេ។ ខែ ១២ ជាកម្មវិធីរបស់រាជរដ្ឋាភិបាលថាឱ្យធ្វើឱ្យចប់ក្នុងខែ ១២ ឆ្នាំ ២០០៦។ ខ្ញុំអត់ដកការងារហ្នឹងទេ ខ្ញុំធ្វើលិខិតមួយហើយទៅនាយកដ្ឋានស្ថិតិ និងអត្តសញ្ញាណប័ណ្ណសូមឱ្យជំនាញចុះមកតែម្តង ព្រោះគ្នាយើងនៅមានក៏រិត អញ្ចឹងការប្រើប្រាស់កុំព្យូទ័រ មិនទាន់បានគ្រប់គ្រាន់នៅឡើយទេ។

លោក ឱក សេរី សោភក្តិ

បញ្ហាដែលខ្ញុំស្តាប់មួយព្រឹកមកមានមតិច្រើនណាស់ ខ្ញុំគិតថាបញ្ហានៃការចែករំលែកព័ត៌មានអាជ្ញាធរដែលចាត់វិធានការហើយ ព័ត៌មានហ្នឹងមិនបានជ្រួតជ្រាបទៅដល់គ្រប់ឃុំ ស្រុក ដូច្នេះហើយបញ្ហាការប្រទាក់ក្រឡា ចែកចាយព័ត៌មានត្រូវយើងសើរើឡើងវិញ។ សូម្បីតែនៅទីនេះបងខាងប៉ូលីសលោកមានផែនការហើយ តែបងខាងកែវសីមាលោកមិនទាន់បានជ្រាប។ ក្នុងរឿងថ្ងៃ ៣០ ខែ ១២ គឺអញ្ចេះទេ ក្នុងឆ្នាំនេះរាជរដ្ឋាភិបាលលោកមានឆន្ទៈនយោបាយ ពិសេសដោយសារយើងបានរួមគ្នាធ្វើយុទ្ធនាការទៅឱ្យអាទិភាពលើបញ្ហាអត្តសញ្ញាណប័ណ្ណជាតិ ខាងក្រសួងមហាផ្ទៃតំណាងរាជរដ្ឋាភិបាលលោកមានផែនការជាឆន្ទៈពិសេសមួយ គឺធ្វើគំហុកតែម្តងនៅឆ្នាំ ២០០៦ នេះ ដើម្បីធ្វើយ៉ាងណា ១ លាន ៩ សែននាក់ហ្នឹងធ្វើឱ្យបានតែម្តង ចប់ថ្ងៃ ៣០ ខែ ១២ ឆ្នាំ ២០០៦។ តែប្រជាពលរដ្ឋមិនអាចចប់បានទេ អាយុ ១៨ ឆ្នាំចេះតែមានតរហូត ដូច្នេះត្រូវតែមានតរហូតតែថាយុទ្ធនាការ ២០០៦ នេះជាយុទ្ធនាការពិសេស ដើម្បីបំរើការងារបោះឆ្នោត ២០០៧ និង ២០០៨ ហើយ នឹងនៅតែធ្វើបន្តទៅទៀត។ នៅក្នុងនេះខ្ញុំបាទសូមជូនជាដំណឹងដោយសារយន្តការដែលយើងបានធ្វើរួមគ្នានេះ អង្គការ UNDP បានសំរេចចិត្ត ជួយនូវថវិកាមួយចំនួនដល់ក្រសួងមហាផ្ទៃ ដើម្បីជំរុញយន្តការនៃការធ្វើអត្តសញ្ញាណប័ណ្ណជាតិ ឱ្យបានមុនថ្ងៃទី ៣០ ខែ ១២។ ឆ្នាំនេះជាឆ្នាំពិសេស តែឆ្នាំក្រោយក្រោយនៅតែធ្វើបន្តទៀត ដូច្នេះរឿងបងស្រីក៏ដោយដែលមានប្រសាសន៍អម្បាញ់មិញ រឿងបងឃុំមានប្រសាសន៍ គឺបញ្ហាទាក់ទងទៅខាងប៉ូលីសលោក មានវិធានការហើយបង្វិលពីឃុំមួយទៅឃុំមួយទៀត។ វិធានការនេះទាល់តែព័ត៌មានបានជ្រួតជ្រាបទៅគ្រប់ឃុំទាំងអស់នៅក្នុងកន្លែងយើងនេះ។

លោក មាំង ឆន អភិបាលរងស្រុកសែនមនោរម្យ មកពីគណបក្សប្រជាជនកម្ពុជា

ជាសំណូមពរពេលដែលចុះឈ្មោះបោះឆ្នោត ព្រោះកន្លងមកប្រជាជនដែលមានអាយុ ១៨ ឆ្នាំគាត់ខ្វះថវិកា បើសិនជាគាត់ទៅថតនៅផ្សារ ៥ 000 ទៅ ១០ 000រៀល អញ្ចឹងខ្ញុំសំណូមពរថាបើយើងធ្វើដូចឆ្នាំ ១៩៩៨ បានឬទេ? កាល ឆ្នាំ១៩៩៨ ខ្ញុំធ្វើបុគ្គលិក CEC ដែរនៅឃុំរមនា កាលណោះយើងថតភ្លាមយកភ្លាម ៤ សន្លឹក។ តើយើងធ្វើអញ្ចឹងបានឬអត់? ព្រោះនៅទីនេះភាគច្រើនអ្នកក្រ។

លោក ឱក សេរី សោភក្តិ៍

ខ្ញុំបាទបានកត់ហើយបញ្ហារូបថត បើសិនជាយើងចង់ឱ្យយុទ្ធនាការអត្តសញ្ញាណប័ណ្ណបានជោគជ័យ ទាល់តែយើងមានលក្ខណៈផ្តល់រូបថតឱ្យគាត់ភ្លាមនៅកន្លែងតែម្តងបានអាចទៅរួច។

លោក សំ សំអាត ស្នងការរងខេត្ត

ចំពោះអត្តសញ្ញាណប័ណ្ណនេះគឺថតផ្ទាល់តែម្តង ដោយមិនបាច់ទៅថតនៅឯណាទេ គេ Scan ជាប់នៅនឹងកាតតែម្តងអត់មានយករូបថតពីក្រៅមកទេ។

លោក ឱក សេរីសោភក្តិ៍

បងវីរៈសេនីទោលោកមានប្រសាសន៍ហើយថា ជាបញ្ហាគោលការណ៍មិនមានយកលុយកាក់ទេនៅក្នុងរឿងហ្នឹង។ ខ្ញុំអរគុណណាស់ដោយសារមួយព្រឹកនេះយើងបានមតិសស្រាក់សស្រាំមែនទែន ទាំងខាងគណបក្សនយោបាយ ទាំងខាងអាជ្ញាធរឃុំ អាជ្ញាធរស្រុក ហើយប្រសាសន៍របស់បងប្រធាន PEC ក៏យើងឮប្រសាសន៍របស់ឯកឧត្តមអភិបាលរងខេត្តក៏យើងបានឮ ខាងអង្គការសង្គមស៊ីវិលក៏យើងបានឮ បងស្រីៗក៏យើងបានឮ ដូច្នេះខ្ញុំបាទ ក្នុងឋានៈជាអ្នកសម្របសម្រួលយន្តការនេះ សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត។

លោក ទី ឈឿន ប្រធានគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្តមណ្ឌលគីរី

តាងនាមឱ្យលេខាធិការដ្ឋានដែលធ្វើការនៅក្នុងខេត្ត ខ្ញុំសូមបកស្រាយនូវសំណួរ ក៏ដូចជាសំណូមពរវាគ្មិន ទាំងអស់ដែលបានលើកព្រឹកនេះ។ ចំពោះតំណាងគណបក្សសមរង្ស៊ីដែលលើកឡើងថា នៅកែវសីមា CEC ឱ្យទៅ ហូបបាយ ១០ នាទី ក្នុងពេលការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ បញ្ហានេះមិនមែនសួរសំដៅតែរឿង CEC ណា ដែលបានអនុវត្តមិនត្រឹមត្រូវ ឬត្រឹមតូវនោះទេ គឺមាន CEC មួយចំនួនបានអនុវត្តទៅតាមការងារភារកិច្ច តាមប្រតិទិន នៃការរៀបចំការបោះឆ្នោតក៏ដូចជាការប្រកាសលទ្ធផល។ បញ្ហាហ្នឹងមិនមែនខ្ញុំសំដៅតែ CEC ណាមួយ គឺ CEC មួយចំនួនដែលបក្សនយោបាយមិនបានធ្វើការងារសង្កេតការណ៍ រង់ចាំការកត់ត្រាលើលទ្ធផលបោះឆ្នោតឱ្យចប់ចុងចប់ដើម មានតែភ្នាក់ងារគណបក្សនយោបាយមួយចំនួនទេ មិនមែនជាទូទៅ។ ចំពោះចំណុច លោក ហ៊ីរ តំណាងគណបក្សសមរង្ស៊ីដែលបានលើកឡើងពីចំណុចការខ្វះខាតហិរញ្ញវត្ថុ ការបាញ់បោះ គឺដំណាក់កាលរៀបចំការបោះឆ្នោត មិនមែនថាអត់ទេការបាញ់បោះនេះ វាមានរឿងផ្សេងៗមិនមែនពាក់ព័ន្ធនឹងការងារនយោបាយទេ។ បញ្ហាថាខ្វះខាតសម្ភារៈ ហិរញ្ញវត្ថុជារឿងផ្ទៃក្នុងរបស់គណបក្ស ដូចលោក ឱក សេរី សោភក្តិ៍ បានលើកឡើងហើយ រឿងនេះជារឿងផ្ទៃក្នុងរបស់គណបក្ស។ ចំពោះការភ័យខ្លាចបើតាមកន្លងមកគឺពុំមានអ្វីដែលគួរឱ្យយើងខ្លាចរអែង រឿងបញ្ហាការគំរាមគំហែងផ្នែកនយោបាយតាមការកត់សំគាល់របស់ខ្ញុំកន្លង

មកពុំមានជាទ្រង់ទ្រាយធំទេ គ្រាន់តែជាការទំនាស់ពាក្យសំដីបន្តិចបន្តួច រួចហើយអ្នកទាំងអស់នោះសួរគ្នា កៀកកគ្នាធម្មតាវិញទេ ។ រឿងការងារនេះមិនមែនជាការងារដែលខ្លាចហើយលែងនិយាយគ្នាក៏មិនមែនដែរ។ ចំពោះអ្នកគ្រូ សេង ខេម នាយិកាសាលាបឋម សែនមនោរម្យ អ្នកស្រីបានសំណូមពរទៅសមាជិកក្រុមប្រឹក្សាឃុំក្នុងការអនុវត្តដំណើរការត្រៀមនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ ក៏ដូចជាការបំពេញទំរង់ ១០២៤ គឺពាក់ព័ន្ធទៅនឹង ១០២៥ ១០២៦ និង១០២៧ អញ្ចឹង ១០២៥ ១០២៦ គឺការផ្លាស់ចេញ ផ្លាស់ចូលអ្នកស្លាប់ ទំរង់ហ្នឹងគឺយើងត្រៀមរយៈពេល ៩ ខែ ពីខែ ០១ រហូតដល់ ខែ ០៩ ត្រូវត្រៀមបណ្តើរៗនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ ដើម្បីដល់ខែ ១០ យើងចាប់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតែម្តង។ អញ្ចឹងបញ្ហាការបំពេញទំរង់នេះគឺជាការបំពេញត្រៀមបំរុងងាយស្រួលយើងពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះក្នុងខែ ១០ រៀងរាល់ឆ្នាំ។ ចំពោះអ្នកស្រី ឡឹម គឹមឡៃន ដែលមានការសំណូមពរមធ្យោបាយធ្វើដំណើរ រឿងថវិកាការឧបត្ថម្ភអ្នកបោះឆ្នោត ក៏ដូចជាផ្តល់សមត្ថភាពនារីឱ្យចូលរួមបំរើការងារឱ្យបានច្រើន។ នីតិវិធីនៃការជ្រើសរើសអ្នកបំរើការងារបោះឆ្នោតនេះ ល័ក្ខខ័ណ្ឌជ្រើសរើសរបស់ គជប មានបើកទូលាយរហូតដល់ឱ្យមានជនជាតិទៀត។ ដូច្នេះការងារនេះទូលំទូលាយណាស់ តែអាស្រ័យនឹងអ្នកមកដាក់ពាក្យមិនដូចបំណងទៅតាមការដែលយើងជ្រើសរើស ជួនកាលអ្នកដែលចង់បាននោះសោតក៏ពុំមានសមត្ថភាពទៀត។ អញ្ចឹងការដែលជ្រើសរើសនេះគឺមានការពិនិត្យពិច័យណាស់។ បញ្ហាថវិការសំរាប់មធ្យោបាយធ្វើដំណើរ គឺរៀងរាល់អណត្តិនៃការបោះឆ្នោតគឺបានសំណូមពរទៅថ្នាក់លើជាពិសេសទៅខាង គជប ច្រើនលើកច្រើនសាណាស់ បញ្ហាការលំបាកខ្លាំងរបស់យើង ទាំងមធ្យោបាយធ្វើដំណើរដឹកសម្ភារៈ យើងដឹងស្រាប់ហើយ ឆ្លងទូក ក្បូន ហែលទឹក ។ ថវិកាដែលយើងត្រូវចំណាយក៏ពាក់ព័ន្ធនឹងការងារដែរ។ បញ្ហាទាំងអស់នេះយើងខ្ញុំបានធ្វើសំណូមពរទៅ គជប ។ មួយទៀតចំពោះបញ្ហាដែលលោក សំ សំអាត ស្នងការរងនគរបាលខេត្តលើកឡើង បញ្ហារឿងការផ្តល់អត្តសញ្ញាណប័ណ្ណក្នុងការធ្វើអត្រានុកូលដ្ឋានរបស់ក្រុមប្រឹក្សាឃុំ ធ្វើយ៉ាងណាសហការគ្នាឱ្យបានញឹកញាប់ ហើយឱ្យជិតស្និតជាមួយនគរបាលប៉ុស្តិ៍នៅតាមឃុំ ក៏ដូចជាក្រុមប្រឹក្សា ឃុំ តាមដានហើយតាមដានទៀតពីការងារនេះចៀសវាងកុំឱ្យមានបញ្ហាដូចជារឿងថាមានការយកលុយកាក់ជាគោលការណ៍គឺអត់មានទេ។ អញ្ចឹងយើងតាមដានការងារនេះឱ្យបានច្បាស់លាស់ផង ព្រោះការធ្វើអត្រានុកូលដ្ឋាន ដើម្បីធ្វើអត្តសញ្ញាណប័ណ្ណនេះគឺទាមទារចាំបាច់សំរាប់ការបោះឆ្នោតរបស់យើងនៅខាងមុខ។ ទិសដៅខាងមុខ គឺអត់មានប្រើប័ណ្ណបោះឆ្នោតដូចការបោះឆ្នោតឆ្នាំ ១៩៩៨ ២០០២ ២០០៣ ទេ អ្វីដែលជាឯកសារផ្លូវការរបស់យើងម្នាក់ៗ មិនថាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមិនថាសៀវភៅគ្រួសារដែលមានបិទរូបថតរបស់សាមីខ្លួន និងឯកសារផ្សេងៗជាច្រើនទៀត។ ចំពោះលោក រិទ្ធិ សុផុន តំណាងឱ្យគណបក្សហ៊្វុន ស៊ិនប៉ិច ដែលលើកឡើងពីបញ្ហាការដឹកជញ្ជូន គណបក្សនយោបាយខ្លះគេមានលទ្ធភាពខ្លះមិនមានលទ្ធភាពបញ្ជូនប្រជាពលរដ្ឋមកបោះឆ្នោត។ បញ្ហានេះក្នុងបទបញ្ញត្តិនីតិវិធីសំរាប់ការឃោសនាបោះឆ្នោត ក៏ដូចជាក្រមសីលធមិសំរាប់គណបក្ស នយោបាយនីមួយៗ គឺការដឹកជញ្ជូនប្រជាពលរដ្ឋមកបោះឆ្នោត បើសិនជាការដឹកជញ្ជូននោះយកឡានឯកជន មិនមែនជាឡានរដ្ឋ ហើយបំរើការផលប្រយោជន៍រួមទាំងអស់គ្នា មិនប្រកាន់ថាបក្សនេះបក្សនោះ ខ្ញុំថាប្រាកដជាគ្មានបញ្ហាទេ។ អញ្ចឹងអាជ្ញាធរភូមិ ឃុំ ត្រូវអព្យាក្រឹត្យលើការងារ បើសិនជាមានករណីដឹកជញ្ជូន។ ហើយយកឡានផ្លាករដ្ឋក៏ត្រូវមានការហាមឃាត់ដែរ។ ចំពោះបញ្ហាលោកស្រី ខាង ជំទប់ទី២ ឃុំស្ពានមានជ័យ ដែលលើកបញ្ហារឿងថាមិនបានទទួល នេះជារឿងផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំទេ ចំពោះយើងខ្ញុំការប្រគល់ឯកសារនីមួយៗមិនមែនថាយើងខ្ញុំមានសិទ្ធិប្រគល់ទេ គឺមានសិទ្ធិតែចុះហត្ថលេខាបញ្ជូនលិខិតតាមផ្នែកកិច្ចការរដ្ឋបាល។ កិច្ចរបស់យើងខ្ញុំឯកសារដែលមានពី គជប មិនទុកឱ្យយូររហូតដល់១-២ថ្ងៃ ទេ ពេលមើលភ្លាមត្រូវបញ្ជូនចេញភ្លាមៗតែម្តង។

ឯកឧត្តម ញ៉ាង ចាន់

ខ្ញុំតំណាងឱ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់នៅខេត្តមណ្ឌលគីរី ខ្ញុំមានកិត្តិយសណាស់ដែរមានគំរោងរបស់វិទ្យាស្ថាន CDRI បានជួបជុំគ្នានៅខេត្តមណ្ឌគីរី ជាការប្រសើរដើម្បីឱ្យយើងខ្ញុំទាំងអស់គ្នាយល់ដឹងពីស្ថានភាព មិនថារដ្ឋអំណាចមូលដ្ឋាន មិនថាអង្គការក្រៅរដ្ឋាភិបាល និងគណបក្សនយោបាយផ្សេងៗដែលមានមុខនៅទីនេះ។ នេះជារឿងបញ្ជាក់ថាមានភាពសប្បាយរីករាយ មានតម្លាភាពសំរាប់ខេត្តនេះដែលកំពុងរកភាពឈានទៅរកការរីកចំរើន ឬនៅក្នុងភូមិសាស្ត្រមួយដែលលំបាកគ្រប់សព្វបែបយ៉ាងទាំងអស់។ ខ្ញុំសូមឯកភាពនិងមតិយោបល់របស់អស់លោក លោកស្រី និងសូមអរគុណដែលមានការគិតមុននិងបញ្ចេញយោបល់។ ខ្ញុំយល់ថាយើងទាំងអស់គ្នាស្តាប់បទអន្តរាគមរបស់វិទ្យាស្ថាន CDRI ដើម្បីឱ្យយើងយល់តទៅទៀត សំខាន់ត្រង់ថាអ្វីនិងធ្វើតាមផ្លូវច្បាប់។ មានច្បាប់ការបោះឆ្នោត ច្បាប់រៀបចំក្រុមប្រឹក្សាឃុំសង្កាត់ ច្បាប់គណបក្សនយោបាយ យើងទាំងអស់គ្នាត្រូវតែអនុវត្តនិងសហប្រតិបត្តិការឱ្យបានល្អប្រសើរ។ ចំពោះវាគ្មិនដែលបាននិយាយអម្បាញ់មិញខ្ញុំសូមបញ្ជាក់ថាបើសិនការបោះឆ្នោតបន្តិចទៀតនេះ យើងគួរតែស្វែងយល់ថែមទៀត ឧបមាថាបញ្ហារឿងចំណេញនយោបាយយើងគិតបានមិនអីទេ ប៉ុន្តែយើងកុំយកបញ្ហានេះមកឈ្លោះគ្នាឬធ្វើបដិបក្ស។ បញ្ហាដឹកប្រជាជនខ្ញុំយល់ថាបើគេមានលទ្ធភាពគេជួលឬយ៉ាងម៉េចមាន នេះមានមែនពេលឃោសនាបោះឆ្នោតអាណត្តិទី២ កាលគេដូរការិយាល័យគេបោះនៅវត្ត ប៉ុន្តែខ្ញុំឮគេនិយាយថា សម រង្ស៊ី ជិះនៅនេះក៏បានប្រជាជនជិះនៅនេះក៏បាន ហ៊្វុនស៊ិនប៉ិច ក៏ជិះបាន។ ប៉ុន្តែក្រោយមកអត់មានទេ ពេលអ៊ុនតាក់ក៏អត់ដែរ ។ ការចែកអំណោយដូចគ្នាដែល ខ្ញុំមានរឿងមួយខាងគណបក្សប្រជាជនចែកអំណោយនៅត្រង់សាលាសុខក្តម ឃើញមានការឈ្លោះគ្នា ប៉ុន្តែអ្នកហូបនំប៉័ង ហ៊្វុនស៊ិនប៉ិចក៏បានប្រជាជនក៏ហូបបាន សមរង្ស៊ី ក៏ហូប បើសិនជាមិនហូបមិនសំខាន់ទេសំខាន់ពេលបោះឆ្នោត បោះឆ្នោតឱ្យអ្នកណាស្រេចតែគេ គេហូបនំប៉័ងគណបក្សប្រជាជន តែគេបោះឱ្យហ៊្វុនស៊ិនប៉ិច។ ខ្ញុំសូមអរគុណណាស់ដែលវាគ្មិនយើងបានលើកឡើង ដើម្បីស្តារអនាគតយើងទាំងអង្គការក្រៅរដ្ឋាភិបាល ទាំងរដ្ឋអំណាចមូលដ្ឋាន ទាំងការិយាល័យបោះឆ្នោត និងជួយសហការណ៍គ្នា ដើម្បីឱ្យប្រជាពលរដ្ឋយើងទាំងអស់គ្នាឋិតនៅក្រោមដំបូលនៃច្បាប់រដ្ឋធម្មនុញ្ញ ដើម្បីឈានទៅអភិវឌ្ឍនប្រទេសជាតិទាល់តែមានការយល់ដឹងអំពីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់រូប។ សិទ្ធិប្រជាពលរដ្ឋសំខាន់គឺរឿងនេះ រឿងខ្លួនឯងបោះឆ្នោតជូនប្រទេសជាតិ ព្រឹទ្ធសភា រដ្ឋសភា ។

លោក ឱក សេរី សោភក្តិ

មួយព្រឹកនេះយើងបានជជែកពិភាក្សាច្រើន ហើយយើងខ្ញុំមកពីវិទ្យាស្ថាន CDRI មានកិត្តិយសណាស់តាមរយៈខប់សែលប្រ៉មនេះ ដែលបានឮប្រសាសន៍ដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកស្រី អស់លោកទាំងអស់ ដែលបានចូលរួមនៅក្នុងអង្គប្រជុំនេះ

-ទី១ យើងបានស្តាប់ប្រសាសន៍លោក ឡារី ស្រេដ្ឋ ដែលលោកបានស្វាគមន៍យ៉ាងកក់ក្តៅក្នុងនាមជានាយកប្រតិបត្តិរបស់វិទ្យាស្ថាន CDRI ។

-ទី២ ខ្ញុំបាទបានជូននូវមូលដ្ឋាន ប្រវត្តិនៃការបង្កើតយន្តការខប់សែលតាំងពីឆ្នាំ ១៩៩៩ រហូតមកដល់ ពេលនេះតំណាក់កាលទី១ ឥឡូវដល់តំណាក់កាលទី២ តាំងពីខប់សែលនៅថ្នាក់ជាតិ រហូតមកដល់ខប់សែលប្រ៉ម ដែលយើងកំពុងធ្វើនៅមណ្ឌលគីរីនេះ។

-ទី៣ យើងបានស្តាប់ប្រសាសន៍ដ៏មានអត្ថន័យរបស់បង ទី ឈឿន ដែលលោករាយការណ៍ពីស្ថានការណ៍ ទាក់ទងទៅនិងយន្តការរៀបចំការបោះឆ្នោតនៅខេត្តមណ្ឌលគីរី។ លោកបានទទួលស្គាល់ដោយស្មោះត្រង់ចំពោះបញ្ហាទាំងឡាយដែលជួបប្រទះកន្លងមកនេះតាមរយៈយន្តការបោះឆ្នោត។

-ទី៤ តំណាងគណបក្សនយោបាយក៏ដោយ សង្គមស៊ីវិលក៏ដោយ គណកម្មការជាតិរៀបចំការបោះឆ្នោតនៅថ្នាក់ខេត្ត នៅថ្នាក់ឃុំ រហូតដល់ថ្នាក់ការិយាល័យបោះឆ្នោតសុទ្ធតែមានកង្វះខាតទាំងអស់គ្នា ជាពិសេសសមត្ថភាពនៅក្នុងការបំពេញភារកិច្ចរបស់

ខ្លួន ។ ដូច្នេះហើយបានជាស្នើសុំមានការរៀបចំជាវគ្គបណ្តុះបណ្តាលរួមគ្នា ដើម្បីឱ្យយល់ច្បាប់ទំលាប់ នីតិវិធី ក្រឹតក្រម ឱ្យដូចៗគ្នា ហើយអនុវត្តទៅតាមអ្វីដែលបានរៀនសូត្រជាមួយគ្នា ។

-ទី៥ បញ្ហាអត្តសញ្ញាណប័ណ្ណជាតិជាបញ្ហាផុសផុល បញ្ហាក្តៅកគុក ហើយដោយសារវិសាលភាពនៃភូមិសាស្ត្រមណ្ឌលគីរីនេះពិបាក ។ ដូច្នេះយើងបានស្តាប់ប្រសាសន៍របស់បងវិរៈសេនីយ៍ទោហើយ លោកនិងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលពិសេសឆ្នាំនេះដើម្បីឈានទៅរកការធ្វើអត្តសញ្ញាណប័ណ្ណជាតិឱ្យបានចប់សព្វគ្រប់ ដូចដែលរាជរដ្ឋាភិបាលលោកមានឆន្ទៈនយោបាយនិងធ្វើ ។

-ទី៦ មានការស្នើសុំនៅពេលដែលរាប់លទ្ធផលបោះឆ្នោត សូមឱ្យតំណាងគណបក្សនយោបាយទាំងអស់ លោកកុំប្រញាប់ទៅផ្ទះ សូមឱ្យនៅចុងចប់ដើម្បីបំពេញបែបបទ ជាពិសេសតារាង ១១០៥ ឱ្យបានដើម្បីជៀសវាងការតវ៉ានៅពេលក្រោយ ។

-ទី៧ មានការទទួលស្គាល់ថា សមាសភាពមន្ត្រីដែលបំរើការឱ្យនៅថ្នាក់ PEC CEC នៅពេលដែលចូល ដល់ការរៀបចំការបោះឆ្នោតខ្លាំងប្រញាប់មែនទែនតួនាទីនៅមិនទាន់មានការច្បាស់លាស់ អាចធ្វើឱ្យកាន់តែច្បាស់លាស់ជាងនេះទៅទៀត ហើយធនធានមនុស្សនៅមានកំរិត និងការបណ្តុះបណ្តាលក៏មានកំរិត ដូច្នេះបងប្រធាន PEC លោកទទួលស្គាល់ថានឹងដោះស្រាយ ទៅតាមហូរហែរ ។

-ទី៨ ទទួលស្គាល់ផងដែរថា សមត្ថភាពដោះស្រាយបណ្តឹងនានានៅមានកំរិតនៅឡើយ កំរិតទាំងធនធានមនុស្ស ទាំងសមត្ថភាព និងចំណេះដឹងក្នុងការដោះស្រាយទាំងនោះកន្លែងនេះម្តងទៀត ខ្ញុំអរគុណដល់បង ទី ឃឿន ណាស់ដែលបងមានប្រសាសន៍ដោយស្មោះត្រង់បែបនេះ ។

-ទី៩ យើងបានទទួលសំណើស្នើសុំអំពី វ៉ាត្ធិន ក៏ដូចជាបង ទី ឃឿនដែរថា សុំធ្វើយ៉ាងណាដើម្បីរើស នៅពេលដែលយើងចូលទៅបំពេញការបោះឆ្នោត ២០០៧ នេះរើសមន្ត្រីគ្រប់ជាន់ថ្នាក់ តាំងពី CEC រហូតដល់ PSO ជាដើម ដើម្បីឱ្យមនុស្សហ្នឹងមានសមត្ថភាពអាចនឹងធ្វើការទាំងនោះបាន បំរើយន្តការនៃការបោះឆ្នោត ។

-ទី១០ នៅពេលមានយុទ្ធនាការបោះឆ្នោត សូមឱ្យគណបក្សនយោបាយទាំងអស់គោរពនូវក្រមសីលធម៌ នៃការឃោសនាបោះឆ្នោត ហើយឯកឧត្តមអភិបាលក៏លោកមានប្រសាសន៍ហើយគឺ សូមធ្វើយ៉ាងណាឱ្យយើងធ្វើទៅតាមក្រឹតក្រមច្បាប់ ដើម្បីជៀសវាងទំនាស់ទាំងឡាយ ។

-ទី១១ បញ្ហាការចែកព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឱ្យបានដល់គ្រប់ឃុំសង្កាត់ទាំងអស់ ។ ក្នុងបញ្ហាព័ត៌មាននេះ យើងឃើញស្រាប់ហើយ បងស្រីជំទប់ទី២លោកបានលើកហើយថា ខាង PEC លោកផ្តល់ឯកសារ ចុះឈ្មោះបោះឆ្នោតទាំងអស់ តែសមាជិកក្រុមប្រឹក្សាឃុំសង្កាត់មិនបានទទួលដឹងឮទាំងអស់គ្នាទេ ដូច្នេះនេះជាបញ្ហាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ប៉ុន្តែគួរតែធ្វើយ៉ាងណាដើម្បីឱ្យមានតម្លាភាពដើម្បីដឹងឮទាំងអស់គ្នា ។ បញ្ហាធ្វើអត្តសញ្ញាប័ណ្ណក្នុងរឿងព័ត៌មាននេះក៏គួរតែចែករំលែកឱ្យបាន ព្រោះពេលវេលាដែលក្រុមយកម៉ាស៊ីនរូបថតយកទៅ ធ្វើនោះមានកំរិត ដូច្នេះហើយត្រូវព័ត៌មានឱ្យបានដឹងដើម្បីសមីប្រជាជនដែលលោកមានអាយុ ១៨ ឆ្នាំ នៅកន្លែងនៅពេលដែលភ្នាក់ងារប៉ូលីសលោកចុះទៅធ្វើ ។

-ទី១២ សុំធ្វើយ៉ាងណាដើម្បីលើកតម្កើងតួនាទីស្ត្រីនៅក្នុងយន្តការបោះឆ្នោតឱ្យបានច្រើន ជាពិសេសស្នើដល់គណបក្សទាំងឡាយសូមឱ្យដាក់បេក្ខជនរបស់ស្ត្រីនៅក្នុងលេខរៀងដែលមានសង្ឃឹមថាអាចនឹងជាប់បំពេញតួនាទី ។

-ទី១៣. បញ្ហាដឹកនាំអ្នកបោះឆ្នោត ដោយសារបញ្ហាភូមិសាស្ត្រនៅមណ្ឌលគីរីនេះជាបញ្ហាធំជាបញ្ហាគន្លឹះ សូមឱ្យកុំមានការប្រកាន់រើសអើង ហើយសូមឱ្យធ្វើសហប្រតិបត្តិការដឹកប្រជាពលរដ្ឋដែលនៅឆ្ងាយដាច់ស្រយាល មកកាន់ទីកន្លែងបោះឆ្នោត ។

-ទី១៤ យើងបានឮដោយរំភើបនូវប្រសាសន៍ប្រកបដោយភាពចាស់ទុំ សន្តិភាពនៅក្នុងប្រសាសន៍ទាំងអស់នោះ គឺ បងស្រីតំណាងខាងគណបក្សសមរង្ស៊ី ក៏ដូចជាលោកអ៊ំខាងគណបក្សហ្វ៊ុនស៊ិនប៉ិចដែរ លោកបានស្នើសុំឱ្យនៅក្នុងគ្រួសារតែមួយទោះបីយើងមានមតិនយោបាយខុសគ្នា ក៏យើងនៅតែជាគ្រួសារតែមួយខ្មែរដូចគ្នា កុំឱ្យការខ្វែងមតិនយោបាយក្លាយទៅជាទំនាស់គ្រួសាររហូតដល់បែកបាក់។ នេះជាប្រសាសន៍ដ៏ថ្លៃថ្លាណាស់ដែលអង្គប្រជុំសូម គោរពហើយទុកជាដំបូន្មានតទៅ។

ខ្ញុំបាទសូមបញ្ចប់ការសរុបកិច្ចពិភាក្សាតែប៉ុណ្ណេះ ហើយសូមជូនពរគ្រឡប់ទៅវិញបន្ទាប់ពីបានទទួលពរ ច្រើនណាស់សូមជូនពរតាងនាមឱ្យក្នុងឋានៈជាអ្នកសំរបសំរួលយន្តការខប់សែលប្រ៉ម សូមបួងសួងដល់គុណបុណ្យ ព្រះរតនត្រៃយ៍ និងទេវតាទាំង មួយម៉ឺនលោកធាតុ សូមជួយថែរក្សាឯកឧត្តម អស់លោក បងស្រី បងប្រុសទាំងអស់ ឱ្យបានជួបប្រទះតែនឹងសេចក្តីសុខ និងពុទ្ធពរទាំង៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណកុំបីឃ្លាងឃ្លាត ឡើយ។

ខ្ញុំបាទសូមជូនការបញ្ចប់ទៅលោក Larry Strange ដើម្បីក្នុងឋានៈលោកជានាយកប្រតិបត្តិរបស់អង្គការ CDRI លោកមានមតិសរុបបញ្ចប់តែម្តង។

លោក Larry Strange

ជាបឋមសូមគោរពឯកឧត្តម អស់លោក លោកស្រីម្តងទៀត ក្នុងនាមវិទ្យាស្ថាន CDRI ខ្ញុំមានមោទនភាព និងសេចក្តីរីករាយណាស់ដែលបានអញ្ជើញឯកឧត្តម អស់លោក លោកស្រីបានចូលរួមក្នុងកិច្ចប្រជុំខប់សែលប្រ៉មថ្ងៃនេះ។ ខ្ញុំសូមអធ្យាស្រ័យពីសំណាក់ឯកឧត្តម អស់លោក លោកស្រីដោយសារអម្បាញ់មិញនេះខ្ញុំបានអវត្តមានបន្តិច ដោយសារតែមានធុរៈជួបជាមួយឯកឧត្តម ឡាយ សុខា អភិបាលខេត្ត ដើម្បីថ្លែងអំណរគុណ និង ចូលសំដែងការគួរសមចំពោះឯកឧត្តមដែលបានអនុញ្ញាតិឱ្យវិទ្យាស្ថាន CDRI ដើម្បីបើកកិច្ចប្រជុំពិភាក្សាអំពីយន្តការដោះស្រាយទំនាស់ក្នុងការបោះឆ្នោត នៅខេត្តមណ្ឌលគីរីនេះ។ ខ្ញុំបានសំដែងការសង្ឃឹមជាមួយនឹងឯកឧត្តមអភិបាល ខេត្តអម្បាញ់មិញនេះថានេះជាការចាប់ផ្តើមមួយដ៏ល្អណាស់រវាងវិទ្យាស្ថាន CDRI និងខេត្តមណ្ឌលគីរីដើម្បីសហការនូវការងារផ្សេងៗទៀតសំរាប់ពេលអនាគតនៅក្នុងខេត្តមណ្ឌលគីរីយើងនេះ។ ខ្ញុំបាទសូមថ្លែងអំណរគុណ ចំពោះអភិបាលរងខេត្តមណ្ឌលគីរី លោកប្រធានគណកម្មការរៀបចំការបោះឆ្នោតខេត្តមណ្ឌលគីរី និងលោកស្នងការរងខេត្តមណ្ឌលគីរី។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះអស់លោក លោកស្រីដែលជាតំណាងពីខាងគណបក្សនយោបាយ អង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធទៅនឹងការងារផ្សេងៗនៅខេត្តមណ្ឌលគីរី តំណាងក្រុមប្រឹក្សា ឃុំ ក៏ដូចជាតំណាងស្រុក តំណាងខាងប៉ូលីស និងតំណាងផ្សេងៗទៀតដែលបានចូលរួមនៅក្នុងនេះ និងចូលរួមក្នុងការពិភាក្សាប្រកបទៅដោយការស្មោះត្រង់ និងត្រង់ទៅត្រង់មក និងមានការគោរពគ្នាយ៉ាងល្អនៅក្នុងពេលនេះ។ ដោយឃើញលក្ខណៈជាក់ស្តែងនៅពេលនេះផ្ទាល់ វិទ្យាស្ថាន CDRI សង្ឃឹមថាបើសិនជាយើងមានការគោរពស្រឡាញ់ និងការពិភាក្សាគ្នាល្អក្នុងលក្ខណៈនេះគឺជាសញ្ញាមួយដែលជំរុញឱ្យមានការអភិវឌ្ឍន៍ដ៏ល្អសំរាប់ប្រទេស។ ក្នុងនាមវិទ្យាស្ថាន CDRI សូមថ្លែងអំណរគុណចំពោះកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ដែលយើងហៅថា UNDP ដែលបានផ្តល់ការគាំទ្រជាហិរញ្ញវត្ថុដល់វិទ្យាស្ថាន CDRI ដើម្បីរៀបចំឱ្យមានកិច្ចប្រជុំខប់សែល តាំងពីថ្នាក់ជាតិ រហូតដល់កិច្ចប្រជុំខប់សែលប្រ៉មនៅថ្នាក់ខេត្ត។ ហើយក៏សូមថ្លែងអំណរគុណផងដែរចំពោះលោក ឱក សេរី សោភក្តិ៍ ដែលបានធ្វើការសំរបសំរួលយ៉ាងប៉ិនប្រសប់នៅក្នុងពេលនេះ ហើយជាពិសេសផងដែរសូមថ្លែងអំណរគុណចំពោះលេខាធិការដ្ឋានរបស់ខប់សែល ដែលបានខិតខំរៀបចំកម្មវិធីនេះឡើង ហើយក៏សូមថ្លែងអំណរគុណ ចំពោះអស់លោក លោកស្រី និងសូមជូនពរដល់ការធ្វើដំណើរទៅវិញនេះប្រកបដោយសុវត្ថិភាព។